# របាយការណ៍លទ្ធផលការងារប្រចាំឆ្នាំ ២០២២
# និងលើកទិសដៅការងារឆ្នាំ ២០២៣ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ

## សេចក្តីផ្តើម

ការងារអភិវឌ្ឍន៍ជនបទ គឺជាកិច្ចការពហុវិស័យត្រូវអនុវត្តនៅមូលដ្ឋានផ្ទាល់ និងត្រូវការពេលវេលាមួយសមស្របក្នុងស្ថានភាពដែលសកលលោក ក៏ដូចជាប្រទេសកម្ពុជាកំពុងជួបនូវបញ្ហាការរីករាលដាលជាសកលនូវជំងឺកូវី-១៩ និងបញ្ហាប្រឈមជាច្រើនទៀត។ ប៉ុន្តែទោះបីជាយ៉ាងណាក៏យើងនៅតែខិតខំពុះពារជំនះគ្រប់បញ្ហា និងឧបសគ្គក្នុងការរៀបចំកិច្ចការអភិវឌ្ឍន៍។

ឆ្នាំ ២០២២ នេះ នៅលើពិភពលោកកំពុងប្រឈមទៅនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ មេរោគនេះជាមេរោគមួយដ៏កាចសាហាវដែលសម្លាប់មនុស្សនៅលើពិភពលោករាប់លាននាក់។ ក្នុងស្ថានភាពនេះ សម្រាប់ប្រទេសកម្ពុជាយើងក៏រងនូវការប្រឈមនឹងហានិភ័យខ្ពស់ នៃការរាតត្បាតនៃជំងឺកូវីដ-១៩ ដែលយើងទាំងអស់គ្នាមន្តប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់ក្នុងការបង្ការ ទប់ស្កាត់នៃការរាតត្បាតនៃជំងឺកូវីដ-១៩ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត។ ស្ថានភាពនៃការរាតត្បាតនៃជំងឺកូវីដ-១៩ នៅលើសកលលោក និងនៅក្នុងតំបន់រួមទាំងប្រទេសកម្ពុជាផងដែរ បានធ្វើឲ្យប៉ះពាល់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ពិសេសការរកទទួលទានរបស់ប្រជាពលរដ្ឋ ដើម្បីចូលរួមដោះស្រាយនូវបញ្ហាប្រឈមសំណើ សំណូមពរ និងការឆ្លើយតបទៅនឹងតម្រូវការជាអាទិភាព របស់ប្រជាជនមូលដ្ឋានជនបទ ក្នុងគោលបំណង លើកកម្ពស់កម្រិតជីវភាពឲ្យកាន់តែប្រសើរឡើង ពីមួយថ្ងៃទៅមួយថ្ងៃ។ ក្រសួងអភិវឌ្ឍន៍ជនបទ ដែលក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ បានដាក់ចេញនូវកម្មវិធីសំខាន់ៗជាយុទ្ធសាស្ត្រចំនួន ៤ គឺ៖ កម្មវិធីទី១៖ ការពង្រឹងស្ថាប័ន និងកសាងសមត្ថភាព, កម្មវិធីទី២៖ អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍, កម្មវិធីទី៣៖កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ និងកម្មវិធីទី៤៖ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ។ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ ប្តេជ្ញាបន្តខិតខំប្រឹងប្រែងអនុវត្តនូវកម្មវិធីដែលក្រសួងអភិវឌ្ឍន៍ជនបទ ផ្តល់ជូនឲ្យទទួលបានជោគជ័យដោយរួមសហការជាមួយអង្គការដៃគូសប្បុរសជន រដ្ឋបាលគ្រប់លំដាប់ថ្នាក់ ដើម្បីប្រែក្លាយទីជនបទឲ្យមានភាពស៊ីវិល័យ។

## I. សមិទ្ធផលសម្រេចបាន

### ១. ការពង្រឹងស្ថាប័ន និងកសាងសមត្ថភាព

#### ១.១. ការងាររដ្ឋបាល និងបុគ្គលិក

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ មានមន្ត្រីបម្រើការងារដើមឆ្នាំ ២០២២ ចំនួន ៥១ នាក់ (ផ្ទេរចេញចំនួន ៣ នាក់)មកដល់បច្ចុប្បន្នសរុបចំនួន ៤៨ នាក់ (ស្ត្រី ១៣ នាក់)ក្នុងនោះរួមមាន៖

- ប្រធានមន្ទីរ ០១ រូប
- អនុប្រធានមន្ទីរ ០៣ រូប
- មន្ត្រីបម្រើការងារនៅតាមការិយាល័យជំនាញទាំង ១០ ការិ.ចំណុះឲ្យមន្ទីរ សរុបមាន ចំនួន ៤៤ រូប ស្រី ១៣ រូប ក្នុងនោះមានមន្ត្រីកិច្ចសន្យាចំនួន ០១ នាក់។

❖ **លិខិតចូលសរុបចំនួន ២៥៦ ច្បាប់ ក្នុងនោះ៖**

- លិខិតចូលពីក្រសួង និងអង្គភាពនានាក្រោមឱវាទមន្ទីរចំនួន ២១១ ច្បាប់។
- លិខិតចូលពីបណ្ដាក្រសួង និងអង្គភាពនានាក្រៅមន្ទីរចំនួន ៤៥ ច្បាប់។

❖ **លិខិតចេញសរុបចំនួន ៦៥៩ច្បាប់ ក្នុងនោះ៖**

- លិខិតចេញទៅបណ្តាអង្គភាពនានាក្រោមមន្ទីរអភិវឌ្ឍន៍ជនបទចំនួន ១៦៣ ច្បាប់។
- លិខិតចេញពាក់ព័ន្ធស្ថានភាពមន្ត្រីរាជការចំនួន ៣៨៥ ច្បាប់។
- លិខិតចេញទៅក្នុងអង្គភាព និងបណ្តាអង្គភាពនានាក្រៅមន្ទីរ ចំនួន ១១១ ច្បាប់។

**១.១.១. សកម្មភាពថ្នាក់ដឹកនាំក្រសួងអភិវឌ្ឍន៍ជនបទ**

- ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០២២ **ឯកឧត្តមបណ្ឌិត សួស គង់** រដ្ឋលេខាធិការប្រចាំការ ក្រសួងអភិវឌ្ឍន៍ជនបទ និងសហការីបានអញ្ជើញចុះពិនិត្យជាក់ស្តែង និងបំពេញនីតិវិធីពាក់ព័ន្ធ និងសំណើសុំគោលការណ៍អនុញ្ញាតកាត់ដីទំហំ ២៦ម x ៣០ម ស្មើនឹង ៧៨០ ម$^{២}$ ដែលស្ថិតនៅបរិវេណមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ ជូនក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា។
- ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០២២ **ឯកឧត្តម សាន វិសាល** រដ្ឋលេខាធិការតំណាងដ៏ខ្ពង់ខ្ពស់**ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីនៃក្រសួងអភិវឌ្ឍន៍ជនបទ អមដំណើរដោយលោកប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក និងសហការីបានចុះត្រួតពិនិត្យការងារបុគ្គលិក ក្នុងគោលបំណងពង្រឹកប្រសិទ្ធិភាពការគ្រប់គ្រងការងារបុគ្គលិកកាន់តែប្រសើរ ស្ថិតនៅសាលប្រជុំធំមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០២២ លោក ពេជ្រ សេដ្ឋា ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងអភិវឌ្ឍន៍ជនបទ ព្រមទាំងសហការីបានចុះត្រួតពិនិត្យធ្វើសវនកម្មប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង និងថវិកាកម្មវិធីឆ្នាំ ២០២១-២០២២ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០២២ **ឯកឧត្តមបណ្ឌិត សួស គង់** រដ្ឋលេខាធិការប្រចាំការ ក្រសួងអភិវឌ្ឍន៍ជនបទ និងសហការីបានអញ្ជើញចូលរួមជាអធិបតីក្នុងកម្មវិធីវេទិកាសាធារណៈ នៃក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានស្រុកភ្នំស្រួច ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាល។
- ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០២២ **ឯកឧត្តមបណ្ឌិត សួស គង់** រដ្ឋលេខាធិការប្រចាំការ នៃក្រសួងអភិវឌ្ឍន៍ជនបទ បានចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ កីឡា

ដ្ឋានខេត្តកំពង់ស្ពឺ ដែលមានទីតាំងស្ថិតនៅភូមិតាម៉ុល សង្កាត់ច្បារមន ក្រុងច្បារមន ខេត្តកំពង់ស្ពឺ។

- ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០២២ **ឯកឧត្តមបណ្ឌិត សួស គង់** រដ្ឋលេខាធិការប្រចាំការ នៃក្រសួងអភិវឌ្ឍន៍ជនបទ បានដឹកនាំគណៈកម្មការអន្តរក្រសួង រួមមានតំណាងក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះត្រួតពិនិត្យវាយតម្លៃ លទ្ធផលការងារថែទាំជាប្រចាំចំនួន ០២ គម្រោង ស្ថិតនៅក្នុងខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០២២ **ឯកឧត្តមបណ្ឌិត សួស គង់** រដ្ឋលេខាធិការប្រចាំការ នៃក្រសួងអភិវឌ្ឍន៍ជនបទ បានអញ្ជើញចូលរួមវេទិកាសាធារណៈ ស្ថិតនៅឃុំអូ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០២២ **ឯកឧត្តមបណ្ឌិត សួស គង់** រដ្ឋលេខាធិការប្រចាំការ នៃក្រសួងអភិវឌ្ឍន៍ជនបទ បានដឹកនាំគណៈកម្មការអន្តរក្រសួង រួមមានតំណាងក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះត្រួតពិនិត្យវាយតម្លៃ ប្រគល់-ទទួល ១០០% ការងារថែទាំខួប ផ្លូវចំនួន ១ ខ្សែ ប្រវែង ១២ ៤៧០ ម ទទឹងខ្នងលើ ៨ ម កម្រាស់ ១,៥០ ម ចាក់ពីភូមិថ្នល់បត់ ដល់ភូមិគង់លើ ក្នុងឃុំខ្ទុំក្រាំង ឃុំជំពូព្រឹក្ស និងឃុំព្រៃក្រសាំង ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ដែល អនុវត្តដោយមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ។

**១.១.២.សកម្មភាពថ្នាក់ដឹកនាំខេត្ត**

- ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០២២ លោក អៀង ដាំ ប្រធានមន្ទីរ និងសហការី បានចូលរួមអមដំណើរ ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត ក្នុងពីធីប្រគល់សម្ភារជូនដល់កម្មករ កម្មការនីរោងចក្រសាប្រ៊ីណា ស្ថិតនៅរោងចក្រសាប្រ៊ីណា។
- ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០២២ លោក អៀង ដាំ ប្រធានមន្ទីរ និងសហការី បានចូលរួមអមដំណើរ ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត ក្នុងពីធីប្រគល់សម្ភារៈជូនដល់កម្មករ កម្មការនីរោងចក្រ ស្ថិតនៅរោងចក្រវ៉ាសាន់។

**១.១.៣ សកម្មភាពក្រុមការងារ (PWG) និងលេខាធិការដ្ឋានក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាត សុខភាពនិងអនាម័យជនបទ (PWG-S)**

- ថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ ២០២២ លេខាធិការដ្ឋាននៃក្រុមការងារបច្ចេកទេសវិស័យទឹកស្អាត សុខភាព និងអនាម័យជនបទ )PWGS) ខេត្តកំពង់ស្ពឺ បានរៀបចំកិច្ចប្រជុំត្រៀមរៀបចំប្រារព្ធពិធីប្រកាសក្រុងច្បារមនជាក្រុងដែលបានបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល (ODF) ក្រោមអធិបតីភាពលោក អៀង ដាំ ប្រធានមន្ទីរ និងជាប្រធានលេខាធិការដ្ឋាន នៅរដ្ឋបាលក្រុងច្បារមនដោយមានការអញ្ជើញចូលរួមពីតំណាងនាយកដ្ឋានថែទាំសុខភាពជនបទ ក្រសួងអភិវឌ្ឍន៍ជនបទ លោក លោកស្រីក្រុមការងារលេខាធិការដ្ឋាន លោក លោស្រីក្រុមការងាររដ្ឋបាលក្រុង លោក លោកស្រី

តំណាងសង្កាត់ទាំង ៥ របស់រដ្ឋបាលក្រុងច្បារមន និងតំណាងអង្គការវ៉ាត់ធើអេដ សរុបចំនួន ១៤ រូប ស្រី ០៤ រូប។

- ថ្ងៃទី ៧ ដល់ ៩ ខែកុម្ភៈ ឆ្នាំ ២០២២ លោក អៀង ដាំ ប្រធានមន្ទីរ និងជាប្រធានលេខាធិការដ្ឋាន PWGs អញ្ជើញជាអធិបតីភាពបើក និងបិទវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ខេត្តក្រុងស្រុកជុំទី៣ "ស្តីពីកម្មវិធីការអប់រំភាពជាអ្នកដឹងនាំ" នៅសាលប្រជុំសាលាខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ២២ ខែ មីនា ឆ្នាំ២០២២ ប្រជុំប្រចាំត្រីមាសទី ១ របស់លេខាធិការដ្ឋាននៃ ក.ក.ផ.ប។
- ថ្ងៃទី ៤ ខែមេសា ឆ្នាំ ២០២២ លោក ប៉ាសួង សៅគន្ធ អនុប្រធានមន្ទីរ ដឹកនាំក្រុមការងារចូលរួមកិច្ចប្រជុំ ស្តីពីពិនិត្យមើលវឌ្ឍនភាពការងារលើកកម្ពស់អនាម័យ និងផែនការបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាលស្រុកថ្ពង រៀបចំដោយនាយកដ្ឋានថែទាំសុខភាព នៅសាលប្រជុំសាលាស្រុកថ្ពង។
- ថ្ងៃទី ៦ ខែឧសភា ឆ្នាំ ២០២២ លោក ប៉ាសួង សៅគន្ធ អនុប្រធានមន្ទីរ ដឹកនាំក្រុមការងារ ចូលរួមកិច្ចប្រជុំ ប្រចាំត្រីមាសទី ១ ឆ្នាំ ២០២២ ស្តីពីការងារទឹកស្អាត សុខភាព និងអនាម័យ នៅសាលប្រជុំសាលាស្រុកសំរោងទង។
- លេខាធិការដ្ឋាននៃក្រុមការងារ PWG-s បានប្រជុំប្រចាំឆ្នាំ ២០២២ បានចំនួន ៤ លើក ក្រោមអធិបតីភាពលោក អៀង ដាំ ប្រធានមន្ទីរ និងជាប្រធានលេខាធិការដ្ឋាន នៅសាលប្រជុំតូចមន្ទីរអភិវឌ្ឍន៍បទខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០២២ ក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាត សុខភាព និងអនាម័យជនបទ) ក.ក.ប.ផ.ទ.អ/PWG) ខេត្តកំពង់ស្ពឺ បានប្រជុំបូកសរុបលទ្ធផលការងារប្រចាំត្រីមាសទី ២ និងលើកទិសដៅត្រីមាសទី ៣ ឆ្នាំ ២០២២ ក្រោមអធិបតីភាព លោក អៀង ដាំ ប្រធានមន្ទីរ និងជាអនុប្រធានក្រុមការងារ ក.ក.ប.ផ.ទ.អ ដោយមានការអញ្ជើញចូលរួមពី ប្រធាននាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ លោក លោកស្រីសមាជិក សមាជិកា PWG, DWG និងក្រុមការងារលេធិការដ្ឋាន សរុបប្រមាណ ៥០រូប ស្រី ១៣ រូប។
- ថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០២២ លេខាធិការដ្ឋាន នៃក្រុមការងារ បច្ចេកទេសវិស័យផ្គត់ទឹកស្អាត សុខភាព និងអនាម័យជនបទ) PWG-S) សហការជាមួយអង្គការវ៉ាត់ធីអេត និងអង្គការយូនីសេហ្វ បានប្រជុំ ឆ្លុះបញ្ចាំងលើវឌ្ឍនភាព បញ្ហាប្រឈម ការរៀនសូត្រ យុទ្ធសាស្ត្រ និងការឆ្ពោះទៅ សម្រេចបាន ODF នៅខេត្តកំពង់ស្ពឺ ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ជ្រុន ថេរ៉ាវ៉ាត** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ និង **ឯកឧត្តម សុខ ភា** អភិបាលរងខេត្ត និងជាប្រធាន PWG ខេត្ត និងសហការី។
- លេខាធិការដ្ឋាន នៃក្រុមការងារ បច្ចេកទេសវិស័យផ្គត់ទឹកស្អាត សុខភាព និងអនាម័យជនបទ) PWG-S) បានចូលរួមកម្មវិធីប្រជុំស្តីពីការពិនិត្យមើលវឌ្ឍនភាពការអនុវត្ត

ផែនការ ODF ភូមិ ឃុំ និងលើកទិសដៅឲ្យសម្រេចបាន ODF នៅដំណាច់ឆ្នាំ ២០២២ ចំនួន ២០ ឃុំ នៅស្រុកគងពិសី និងស្រុកសំរោងទង ។

**១.១.៤.សកម្មភាពថ្នាក់ដឹកនាំមន្ទីរ**

- ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០២២ លោក ប៉ាសួង សៅគន្ធ អនុប្រធានមន្ទីរ បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សា និងរៀបចំឯកសារប្រលងប្រណាំងទីក្រុងស្អាតឆ្នាំ ២០២២-២០២៥ ស្ថិតនៅសាលប្រជុំមន្ទីរទេសចរណ៍។
- ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០២២ លោក អៀង ដាំ ប្រធានមន្ទីរ និងលោក អ៊ុំ សារឿន បានចូលរួមក្នុងសិក្ខាសាលាស្តីពីការរៀបចំគម្រោងកម្មវិធីវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល ២០២៣-២០២៥ របស់ក្រសួងអភិវឌ្ឍន៍ជនបទ តាមប្រព័ន្ធអនឡាញ។
- ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០២២ លោក ចិន ជឹម អនុប្រធានមន្ទីរ បានចូលរួមស្តីពីការរៀបចំវេទិកាសាធារណៈប្រចាំឆ្នាំ ២០២២ របស់ក្រុមការងារថ្នាក់ជាតិចុះជួយមូលដ្ឋានស្រុកបសេដ្ឋខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០២២ លោក ប៉ាសួង សៅគន្ធ អនុប្រធានមន្ទីរ និងលោក អ៊ុង ពន្លា បានចូលរួមក្នុងសិក្ខាសាលាបូកសរុបលទ្ធផលការងារដែលសម្រេចបានក្នុងឆ្នាំ ២០២១ និងលើកទិសដៅការងារបន្ត លើវិស័យផ្គត់ផ្គង់ទឹក ការសម្អាត និងអនាម័យជនបទ ស្ថិតនៅសណ្ឋាគារ សាន់វេ ភ្នំពេញ។
- ថ្ងៃទី ២៧-២៨ ខែមករា ឆ្នាំ ២០២២ លោក អៀង ដាំ ប្រធានមន្ទីរ លោក អ៊ុំ សារឿន និងលោក ញ៉ែម ស្រស់ បានចូលរួមសិក្ខាសាលាបណ្តុះបណ្តាលស្តីពីគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាព័ត៌មានសមិទ្ធកម្មរបស់ក្រសួងអភិវឌ្ឍន៍ជនបទ តាមប្រព័ន្ធអនឡាញ។
- ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០២២ លោក អៀង ដាំ ប្រធានមន្ទីរបានចូលរួមពិធីប្រកាសស្រុក៤ គឺស្រុកអង្គស្នួល ស្រុកកណ្តាលស្ទឹង ស្រុកខ្សាច់កណ្តាល និងស្រុកលើកដែក ខេត្តកណ្តាល ជាស្រុកសម្រេចបាន ODF ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ។
- លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ និងសហការី បានចូលរួមប្រជុំត្រួតពិនិត្យរបាយការណ៍ប្រចាំខែ និងលើកទិសដៅបន្ត ប្រចាំឆ្នាំ ២០២២ ស្ថិតនៅសាលប្រជុំសាលាខេត្ត អគារ ខ បានចំនួន ១២ លើក។
- ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០២២ លោក អៀង ដាំ ប្រធានមន្ទីរបានចូលរួមក្នុងកិច្ចប្រជុំបូកសរុបការងារប្រចាំឆ្នាំ របស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ស្ពឺ តាមរយៈ Zoom Meeting។

- ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០២២ លោក អៀង ដាំ ប្រធានមន្ទីរបានចូលរួមជាគណៈអធិបតី ក្នុងកម្មវិធីបើក វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ខេត្ត ក្រុង ស្រុក នៃកម្មវិធីការអប់រំភាពជាអ្នកដឹកនាំជុំទី៣ ស្ថិតនៅសាលប្រជុំសាលាខេត្ត អគារ គ។
- ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ២០២២ លោក អៀង ដាំ ប្រធានមន្ទីរបានចូលរួមប្រជុំសាមញ្ញលើកទី ២៩ អាណត្តិទី ៣ របស់ក្រុមប្រឹក្សាខេត្ត តាមរយៈប្រព័ន្ធអនឡាញ។
- ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០២២ លោក អៀង ដាំ ប្រធានមន្ទីរបានចូលរួមជាគណៈអធិបតី ក្នុងកម្មវិធីបិទ និងចែកវិញ្ញាបនបត្រជូនសិក្ខាកាម ក្នុងវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ខេត្ត ក្រុង ស្រុក នៃកម្មវិធីការអប់រំភាពជាអ្នកដឹកនាំជុំទី ៣ ស្ថិតនៅសាលប្រជុំសាលាខេត្ត អគារ គ។
- ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ បានចូលរួមក្នុងកិច្ចផ្សព្វផ្សាយ ស្តីពីការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរក្នុងវិស័យទេសចរណ៍ ស្ថិតនៅសាលប្រជុំមន្ទីរទេសចរណ៍ខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០២២ លោក អៀង ដាំ បានចូលរួមវេទិកាសាធារណៈជាមួយប្រជាពលរដ្ឋដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធី នយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ថិតនៅសាលាឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០២២ លោក អៀង ដាំ ប្រធានមន្ទីរ បានចូលរួមក្នុងកិច្ចប្រជុំត្រៀមរៀបចំសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ របស់រដ្ឋបាលខេត្ត ប្រជុំតាមរយៈប្រព័ន្ធអនឡាញ។
- ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០២២ លោក អៀង ដាំ ប្រធានមន្ទីរ បានចូលរួមក្នុងពិធីប្រគល់ផ្ទះ១ខ្នង ជាអំណោយដ៏ថ្លៃថ្លារបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ជូនលោកយាយ ឌួង តារាណុបណែម និងចែកអំណោយចំនួន ៤៥ គ្រួសារ។
- ថ្ងៃទី ១៦-១៨ ខែកុម្ភៈ ឆ្នាំ២០២២ លោក ប៉ាសួង សៅគន្ធ អនុប្រធានមន្ទីរ និងលោក វណ្ណ ចន្ថា បានចូលរួមការប្រជុំ ប្រចាំឆ្នាំ រវាង អង្គការវ៉ែតធើរអេត និងដៃគូទាំងអស់ របស់អង្គការវ៉ែតធឺអេតប្រចាំប្រទេសកម្ពុជា ស្ថិតនៅសណ្ឋាគារ សាន់វេ ភ្នំពេញ។
- ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ និងសហការី បានចូលរួមក្នុងពិធីបុណ្យមាឃបូជា ស្ថិតនៅវត្តមុនីវង្សីរតនារាម ខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០២២ លោក ចិន ជឹម អនុប្រធានមន្ទីរបានចូលរួមវេទិកាសាធារណៈ នៅឃុំពោធិចំរើន ស្រុកបសេដ្ឋ។

- ថ្ងៃទី ០២ ខែ មីនា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ បានចូលរួមទទួលជួបជាមួយគណៈកម្មការទី ៣ នៃរដ្ឋសភា ស្ថិតនៅសាលប្រជុំសាលាខេត្ត អគារ ខ។
- ថ្ងៃទី ០៣ ខែមីនា ឆ្នាំ ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ បានចូលរួមប្រជុំត្រួតពិនិត្យរបាយការណ៍ប្រចាំខែកុម្ភៈ និងលើកទិសដៅការងារខែមីនា ឆ្នាំ ២០២២ តាមរយៈប្រព័ន្ធអនឡាញ។
- ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ បានចូលរួមប្រជុំរវាងគណៈកម្មការផែនការវិនិយោគកសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក នៃរដ្ឋសភា ស្ថិតនៅសាលប្រជុំសាលាខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ១០ ខែមីនា ឆ្នាំ២០២២ លោក អៀង ដាំ ប្រធានមន្ទីរ បានចូលរួមប្រជុំសាមញ្ញលើកទី ៣០ អាណត្តិ ៣ របស់ក្រុមប្រឹក្សាខេត្ត តាមរយៈប្រព័ន្ធអនឡាញ។
- ថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០២២ លោក ប៉ាសួង សៅគន្ធ អនុប្រធានមន្ទីរ បានចូលរួមក្នុងពិធីបញ្ចុះសីមា និងសម្ពោធសមិទ្ធផលនានាក្នុងវត្តក្រាំងវត្តៃ ស្ថិតនៅឃុំញ្ញាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ
- ថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០២២ លោក ប៉ាសួង សៅគន្ធ អនុប្រធានមន្ទីរបានចូលរួមក្នុងពិធីបើកសម្ពោធពិព័រណ៍ពាណិជ្ជកម្មខេត្តកំពង់ស្ពឺ លើកទី ០៩ ឆ្នាំ ២០២២ ស្ថិតនៅមន្ទីរពាណិជ្ជកម្មខេត្ត។
- ថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០២២ លោក អៀង ដាំ ប្រធានមន្ទីរ បានចូលរួមប្រជុំសាមញ្ញលើកទី ៣០ អាណត្តិ ៣ របស់ក្រុមប្រឹក្សាខេត្ត តាមរយៈប្រព័ន្ធអនឡាញ។
- ថ្ងៃទី ២៨-២៩ ខែមីនា ឆ្នាំ២០២២ លោក អៀង ដាំ ប្រធានមន្ទីរ បានចូលរួមពិធីបើកនិងបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ របស់រដ្ឋបាលខេត្តកំពង់ស្ពឺ ស្ថិតនៅសាលាខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរបានចូលរួមក្នុងពិធីរៀបចំយុទ្ធនាការអប់រំផ្សព្វផ្សាយច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ស្ថិតនៅសាលប្រជុំរបស់មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០២២ លោក អៀង ដាំ ប្រធានមន្ទីរបានចូលរួមប្រជុំសាមញ្ញលើកទី ៣១ អាណត្តិទី ៣ របស់ក្រុមប្រឹក្សាខេត្ត តាមរយៈប្រព័ន្ធអនឡាញ។
- ថ្ងៃទី ១១ ខែ មេសា ឆ្នាំ២០២២ លោក ប៉ាសួង សៅគន្ធ អនុប្រធានមន្ទីរបានចូលរួមពិសាអាហារសាមគ្គីអបអរឆ្នាំថ្មី ស្ថិតនៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ២០២២ លោក អៀង ដាំ ប្រធានមន្ទីរបានចូលរួមកិច្ចប្រជុំថ្នាក់ក្រោមជាតិ ដើម្បីពន្លឿនការបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាលនៅកម្ពុជា ស្ថិតនៅខេត្តព្រះសីហនុ។

- ថ្ងៃទី ១១ ខែ មេសា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ បានចូលរួមពិសាអាហារសាមគ្គីអបអរឆ្នាំថ្មី ស្ថិតនៅមន្ទីរសាធារណៈការ និងដឹកជញ្ជូន។
- ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០២២ លោក ប៉ាសួង សៅគន្ធ អនុប្រធានមន្ទីរ បានចូលរួមក្នុងពិសីក្រុងពាលីសង្ក្រានឆ្នាំថ្មី ក្នុងខេត្តកំពង់ស្ពឺ នៅបរិវេណមុខប្រាសាទព្រះនរាយន៍។
- ថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០២២ លោក ប៉ាសួង សៅគន្ធ អនុប្រធានមន្ទីរ បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយ និងពិគ្រោះយោបល់អំពីសេវាសាធារណៈលើការផ្តល់សេវាកម្មបូម និងសម្អាតភក់ពីអាងសិបទិច ការផ្តល់សេវាសម្អាតប្រមូលដឹកជញ្ជូន និងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០២២ លោក អៀង ដាំ ប្រធានមន្ទីរ បានចូលរួមទទួលជួបជាមួយគណៈកម្មការទី ៣ នៃព្រឹទ្ធសភា ស្ថិតនៅសាលប្រជុំសាលាខេត្ត អគារ ខ។
- ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ បានចូលរួមទិវាជាតិប្រយុទ្ធនិងជំងឺគ្រុនចាញ់ក្រោមប្រធានបទ រួមគ្នាអនុវត្តគន្លងសកម្មភាពថ្មីៗឈានទៅកាត់បន្ថយបន្ទុកជំងឺគ្រុនចាញ់សកល ដើម្បីលើកកម្ពស់សុខមាលភាព ស្ថិតនៅវត្តចំបក់ ឃុំចំបក់ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន និងលោក ញ៉ែម ស្រស់ បានចូលរួមប្រជុំបិទរបាយការណ៍សវនកម្ម ជាមួយប្រធានប្រតិភូអាជ្ញាធរសវនកម្មជាតិ និងរដ្ឋបាលខេត្តកំពង់ស្ពឺ សម្រាប់ឆ្នាំ ២០២១ និងឆ្នាំពាក់ព័ន្ធ ស្ថិតនៅសាលប្រជុំ តាមរយៈប្រព័ន្ធអនឡាញ។
- ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ បានចូលរួមក្នុងពិធីប្រកាសផ្ទេរភារកិច្ចថ្នាក់ដឹកនាំប្រធានសាខាពន្ធដារខេត្ត ស្ថិតនៅសាលប្រជុំសាលាខេត្ត អគារ ខ។
- ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០២២ លោក អៀង ដាំ ប្រធានមន្ទីរ និង លោក ប៉ាសួង សៅគន្ធ អនុប្រធានមន្ទីរ និងសហការី បានចូលរួមកម្មវិធីប្រកាសទទួលស្គាល់ខេត្តស្វាយរៀងបញ្ឈប់បន្ទោបង់ពាសវាលពាសកាល ស្ថិតនៅខេត្តស្វាយរៀង។
- ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ បានចូលរួមប្រជុំស្តីពីការជ្រើសរើសបេក្ខភាពភូមិទេសចរណ៍ឆ្នើមឱ្យចូលរួមក្នុងការប្រកួតប្រជែងភូមិទេសចរណ៍ឆ្នើម របស់អង្គការ UNWTO ឆ្នាំ ២០២២។
- ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០២២ លោក អៀង ដាំ ប្រធានមន្ទីរបានចូលរួមក្នុងកិច្ចប្រជុំសាមញ្ញលើកទី ៣២ អាណត្តិទី ៣ របស់ក្រុមប្រឹក្សាខេត្ត តាមរយៈVideo Zoom។
- ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ បានចូលរួមក្នុងពិធីផ្តល់ប័ណ្ណកម្មសិទ្ធិ ដីធ្លីជូនគ្រួសារយោធិន អតីតយុទ្ធជន និងប្រជាពលរដ្ឋ នៅ

មជ្ឈមណ្ឌលហ្វឹកហ្វឺនកងទ័ពជើងគោក ស្ថិតនៅមជ្ឈមណ្ឌលហ្វឹកហ្វឺនកងគោគ ស្ថិតនៅភូមិទី ៦ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

- ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០២២ លោក ប៉ាសួង សៅគន្ធ អនុប្រធានមន្ទីរ បានចូលរួមក្នុងកិច្ចប្រជុំឆ្លងផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្ម ២០២១-២០២៥ នៅសាលប្រជុំអគារ គ សាលាខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ និងសហការីបានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីមូលដ្ឋានគ្រឹះការគ្រប់គ្រង និងថែទាំ ហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ ស្ថិតនៅសណ្ឋាគារសុខាល័យអង្គរ ខេត្តសៀមរាប។
- ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ២០២២ លោក ប៉ាសួង សៅគន្ធ អនុប្រធានមន្ទីរ និងបានចូលរួមក្នុង ពិធីផ្តល់ប័ណ្ណកម្មសិទ្ធដីធ្លីជូនគ្រួសារយោធិន អតីតយុទ្ធជន និងប្រជាពលរដ្ឋនៅមជ្ឈមណ្ឌលហ្វឹកហ្វឺនកងទ័ពជើងគោក ស្ថិតនៅមណ្ឌលហ្វឹកហ្វឺនកងទ័ពជើងគោគ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ បានចូលរួមក្នុងកិច្ចប្រជុំស្តីពីការរៀបចំបង្កើតក្រុមការងារដឹកនាំសម្របសម្រួលវិស័យសន្តិសុខស្បៀង និងអាហាររូបត្ថម្ភខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ បានចូលរួមក្នុងពិធីដាំដើមឈើ នៅមជ្ឈមណ្ឌលវប្បធម៌ព្រះពុទ្ធសាសនាកម្ពុជា ឧទ្យានជាតិព្រះសុរាម្រិតកុសុមៈគីរីរម្យ ស្ថិតនៅភូមិថ្មី ឃុំចំបក់ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០២២ លោក អៀង ដាំ ប្រធានមន្ទីរ បានចូលរួមក្នុងកិច្ចប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត ស្ថិតនៅសាលប្រជុំសាលាខេត្ត។
- ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ បានចូលរួមក្នុងការប្រារព្វទិវាកុមារអន្តជាតិ ១ មិថុនា ឆ្នាំ២០២២ ស្ថិតនៅសាលប្រជុំបណ្ណាល័យកំពង់ស្ពឺ។
- ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២២ លោក អៀង ដាំ ប្រធានមន្ទីរ បានចូលរួមក្នុងកិច្ចប្រជុំសាមញ្ញលើកទី៣៣ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្ត តាមរយៈVideo Zoom។
- ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ បានចូលរួមក្នុងពិធីប្រកាសផ្ទេរភារកិច្ច និងតែងតាំងអភិបាលនៃ គណៈអភិបាលក្រុងច្បារមន ស្ថិតនៅសាលាក្រុងច្បារមន។
- ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ លោក អៀង ដាំ ប្រធានមន្ទីរ និងសហការីបានចូលរួមកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងនីតិវិធីនៃការផ្តល់ទិដ្ឋាការលើការផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការស៊ីវិលនៅថ្នាក់ក្រោមជាតិ ស្ថិតនៅសាលប្រជុំសាលាខេត្ត អគារខ។

- ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០២២ លោក ចិន ជឹម អនុប្រធានមន្ទីរ បានចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈលើកទី៥ ឆ្នាំ ២០២២ ស្ថិតនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០២២ លោក អៀង ដាំ ប្រធានមន្ទីរ បានចូលរួមក្នុងកិច្ចប្រជុំគណៈអភិបាលខេត្តកំពង់ស្ពឺស្ថិតនៅសាលប្រជុំសាលាខេត្ត អគារ ខ។
- ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០២២ លោក ប៉ាសួង សៅគន្ធ អនុប្រធានមន្ទីរ លោក ញ៉ែម ស្រស់ លោក អ៊ុំ សារឿន និងលោក នឹម ប៊ុនថេន បានចូលរួមសិក្ខាសាលាស្តីពីការរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ ២០២៣-២០២៥ និងថវិកាសមិទ្ធកម្មឆ្នាំ ២០២៣ នៅសណ្ឋាគារសុខា ខេត្តព្រះសីហនុ។
- ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ បានចូលរួមក្នុងកិច្ចប្រជុំសម្រេចផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម ២០២១-២០២៥ខេត្តកំពង់ស្ពឺ នៅសាលប្រជុំសាលាខេត្ត អគារ គ។
- ថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០២២ លោក អៀង ដាំ ប្រធានមន្ទីរ បានចូលរួមក្នុងកិច្ចប្រជុំគណៈអភិបាលខេត្តកំពង់ស្ពឺ ស្ថិតនៅសាលប្រជុំសាលាខេត្ត អគារខ។
- ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ លោក អ៊ុង រស់រ៉ាមី និងលោក អ៊ុំ សារឿន បានចូលរួមប្រជុំការងារកសាងផែនការបីឆ្នាំរំកិលថែទាំផ្លូវលក្ខណៈខួបប្រចាំ និងថែទាំផ្លូវកៅស៊ូ លក្ខណៈប្រចាំ ស្ថិតនៅក្រសួងអភិវឌ្ឍន៍ជនបទ។
- ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ ជាវាគ្មិនក្នុងវេទិកាសាធារណៈរបស់ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានស្រុកឱរ៉ាល់ ស្ថិតនៅវត្តកន្ទួតឃុំសង្កែទាប។
- ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២ លោក ចិន ជឹម អនុប្រធានមន្ទីរបានចូលរួមប្រជុំប្រចាំខែមិថុនា ឆ្នាំ២០២២ របស់គម្រោង Cash for work ស្ថិតនៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ។
- ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២២ លោក ប៉ាសួង សៅគន្ធ អនុប្រធានមន្ទីរ បានចូលរួមក្នុងកិច្ចប្រជុំជាមួយក្រុមការងារកម្រិតបច្ចេកទេសរបស់ វ.ស.ស ក្នុងគោលបំណងពង្រឹងនិងពង្រីកភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិល ស្ថិតនៅសណ្ឋាគារផាមរីវើ ខេត្តកំពង់ស្ពឺ។
- ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ បានចូលរួមប្រជុំបំពាក់បំប៉ន ដោយផ្ទាល់លើការអនុវត្តការងារចងក្រងសមាជិកចលនាភូមិមួយផលិតផលមួយ ស្ថិតនៅសាលប្រជុំសាលាខេត្ត អគារគ។
- ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរបានចូលរួមក្នុងទិវាប្រជាជនពិភពលោក ១១ កក្កដា លើកទី៣៣ តាមប្រព័ន្ធអនឡាញ។

- ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០២២ លោក ប៉ាសួង សៅគន្ធ អនុប្រធានមន្ទីរ និងសហការី បានចូលរួមកិច្ចប្រជុំពិភាក្សាកម្រិតបច្ចេកទេសលើគម្រោងផែនការចំណូល-ចំណាយ ថវិកាឆ្នាំ២០២៣ស្ថិតនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ បានចូលរួមក្នុង ពិធីបុណ្យរុក្ខទិវា ០៩ កក្កដា ឆ្នាំ២០២២ ស្ថិតនៅភូមិអង្វេ ឃុំក្រាំងអំពិល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរបានចូលរួមក្នុង កិច្ចប្រជុំស្តីពី សក្តានុពលខេត្តកំពង់ស្ពឺ ស្ថិតនៅសាលប្រជុំអគ្គារ គ។
- ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ បានចូលរួមក្នុង កម្មវិធីបើកសម្ពោធពិព័រពាណិជ្ជកម្មខេត្តកំពង់ស្ពឺលើកទី ១០ ឆ្នាំ២០២២ ស្ថិតនៅ បរិវេណមន្ទីរពាណិជ្ជកម្មខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ បានចូលរួមជា វាគ្មិនក្នុងវេទិកាសាធារណៈរបស់ ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានស្រុកឱរ៉ាល់ ស្ថិតនៅ សាលាឃុំហោងសំណំ។
- ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ បានចូលរួមពិធី ផ្សព្វផ្សាយ ការដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំង ឡាយ ដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ ស្ថិតនៅបណ្ណាល័យខេត្ត កំពង់ស្ពឺ។
- ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ បានចូលរួមប្រជុំ បូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ ឆ្នាំ២០២២ របស់ក្រុមការងាររាជរដ្ឋាភិបាល ចុះមូលដ្ឋានស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ស្ថិតនៅសាលាស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ បានចូលរួមកិច្ច ប្រជុំស្តីពីការពិនិត្យ និងអនុម័តលើសំណើរគម្រោងខេត្តឆ្នាំ២០២២ ស្ថិតនៅសាលប្រជុំ សាលាខេត្ត អគារ ខ។
- ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ បានចូលរួមក្នុង ពិធីអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ស្ថិតនៅសាលប្រជុំ សាលាខេត្ត អគារ ខ។
- ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០២២ លោក ប៉ាសួង សៅគន្ធ លោក ប៉ុក ចាន់ថន និងលោក ចិន ជឹម បានចូលរួមវេទិកាសាធារណៈជាមួយប្រជាពលរដ្ឋដើម្បីត្រួតពិនិត្យ និងគាំទ្រ ការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ថិតនៅសាលាឃុំមហាសាំង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ និង លោក ជួប កំសត់ បានចូលរួមទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោក ០៩ សីហា លើកទី

២៨ និងនៅកម្ពុជាលើកទី១៨ ឆ្នាំ២០២២ ស្ថិតនៅភូមិកោដូនតី ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។

- ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០២២ លោក អៀង ដាំ ប្រធានមន្ទីរបានចូលរួមកិច្ចប្រជុំសាមញ្ញលើកទី៣៥ អាណត្តិទី០៣ របស់ក្រុមប្រឹក្សាខេត្ត តាមរយៈប្រព័ន្ធអនឡាញ។
- ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០២២ លោក អៀង ដាំ ប្រធានមន្ទីរបានចូលរួមក្នុងសិក្ខាសាលាស្តីពីការពង្រឹងប្រសិទ្ធភាព នៃការកាត់បន្ថយការលេចធ្លាយចំណូលពីការប្រើប្រាស់ផលិតផលរ៉ែសំណង់សម្រាប់គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋ និងការពង្រឹងភាពអនុលោមលើការធ្វើប្រតិបត្តិការធនធានរ៉ែ ស្ថិតនៅអគ្គនាយកដ្ឋានប្រេងកាត។
- ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០២២ លោក ប៉ាសួង សៅគន្ធ អនុប្រធានមន្ទីរ រួមទាំងសហការីបានចូលរួមសិក្ខាសាលា ស្តីពីលទ្ធផលនៃការវាយតម្លៃការបញ្ចៀសភាពធន់ នឹងអាកាសធាតុនៅក្នុងកម្មវិធីទឹកស្អាត និងអនាម័យ ស្ថិតនៅខេត្តតាកែវ។
- ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០២២ លោក អៀង ដាំ ប្រធានមន្ទីរបានចូលរួមក្នុងពិធីប្រគល់សម្ភារៈជូនដល់កម្មករ កម្មការនីរោងចក្រ ស្ថិតនៅរោងចក្រវ៉ាសាន់។
- ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ បានចូលរួមក្នុងកិច្ចប្រជុំសម្រេចផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្ម ២០២១-២០២៥ ស្ថិតនៅសាលប្រជុំសាលាខេត្ត អគារ គ។
- ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន ប្រធានមន្ទីរ បានចូលរួមក្នុងពិធីប្រកាសតែងតាំងមន្ត្រីរាជការ ជាអភិបាលរង នៃគណៈអភិបាលខេត្តកំពង់ស្ពឺ ស្ថិតនៅសាលប្រជុំសាលាខេត្ត អគារខ។
- ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ បានចូលរួមក្នុងពិធីប្រកាសតែងតាំង អភិបាលនៃគណៈអភិបាលស្រុកសំរោងទង ស្ថិតនៅសាលប្រជុំសាលាស្រុកសំរោងទង។
- ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ បានចូលរួមប្រជុំត្រួតពិនិត្យរបាយការណ៍ប្រចាំខែ សីហា និងលើកទិសដៅខែកញ្ញា ឆ្នាំ២០២២ ស្ថិតនៅសាលប្រជុំសាលាខេត្ត អគារ ខ។
- ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ២០២២ លោក ចិន ជឹម អនុប្រធានមន្ទីរ បានចូលរួមក្នុងពិធីក្រុងពាលីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការកីឡាដ្ឋានខេត្តកំពង់ស្ពឺស្ថិតនៅ កីឡាដ្ឋានខេត្តកំពង់ស្ពឺ
- ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០២២ លោក ចិន ជឹម អនុប្រធានមន្ទីរ និងសហការី បានចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ កីឡាដ្ឋានខេត្តកំពង់ស្ពឺ ស្ថិតនៅ កីឡាដ្ឋានខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ២០២២ លោក អៀង ដាំ ប្រធានមន្ទីរ បានចូលរួមកិច្ចប្រជុំសាមញ្ញលើកទី ៣៦ អណត្តិទី០៣ របស់ក្រុមប្រឹក្សាខេត្ត តាមរយៈប្រព័ន្ធអនឡាញ។

- ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ២០២២ លោក អៀង ដាំ ប្រធានមន្ទីរ បានចូលរួមកិច្ចប្រជុំសាមញ្ញលើកទី ៣៦ អណត្តិទី០៣ របស់ក្រុមប្រឹក្សាខេត្ត តាមរយៈប្រព័ន្ធអនឡាញ។
- ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០២២ លោក ប៉ាសួង សៅគន្ធ អនុប្រធានមន្ទីរបានចូលរួមកិច្ចប្រជុំបូកសរុបវឌ្ឍនភាពការងារត្រីមាសទី៣ ឆ្នាំ២០២២ និងទិសដៅបន្តរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០២២ លោក អៀង ដាំ ប្រធានមន្ទីរ បានចូលរួមកិច្ចប្រជុំឆ្លុះបញ្ចាំង លើវឌ្ឍនភាព បញ្ហាប្រឈម ការរៀនសូត្រ យុទ្ធសាស្ត្រ និងការឆ្ពោះទៅសម្រេចបាន ODF នៅខេត្តកំពង់ស្ពឺ ស្ថិតនៅសណាគារ Palm River។
- ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០២២ លោក អៀង ដាំ ប្រធានមន្ទីរ បានចុះត្រួតពិនិត្យវាយតម្លៃ ប្រគល់-ទទួល១០០% ការងារថែទាំខួប ផ្លូវចំនួន១ខ្សែ ប្រវែង ១២៤៧០ម ទទឹងខ្នងលើ ៨ម កម្រាស់ ១,៥០ម ចាក់ពីភូមិថ្នល់បត់ ដល់ភូមិគង់លើ ក្នុងឃុំខ្ញុំក្រាំង ឃុំជំពូព្រឹក និងឃុំព្រៃក្រសាំង ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ដែល អនុវត្តដោយមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ និងលោក ដួប កំសត់ បានចូលរួមទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោក លើកទី២៨ និងលើកទី១៨នៅកម្ពុជា ស្ថិតនៅខេត្តក្រចេះ។
- ថ្ងៃទី ២៨-៣០ ខែ កញ្ញា ឆ្នាំ២០២២ លោក ប៉ាសួង សៅគន្ធ លោក អ៊ុំ សារឿន និងលោក លឹម ម៉ាឡែន បានចូលរួមក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការត្រួតពិនិត្យផែនការសុវត្ថិភាពទឹក និងអនាម័យ ស្ថិតនៅខេត្តកំពត។
- ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ២០២២ លោក ចិន ជឹម អនុប្រធានមន្ទីរបានចូលរួមចុះពិនិត្យទីតាំងស្នើរសុំដីសម្បទានដីសង្គមកិច្ចរបស់គម្រោងបែងចែកដីដើម្បីអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច ដំណាក់កាលទី៣ ស្ថិតនៅឃុំតាសាល និងឃុំត្រពាំងជោរ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ០១ ខែ តុលា ឆ្នាំ២០២២ លោក ប៉ាសួង សៅគន្ធ លោក ប៉ុក ចាន់ថន និងលោក ចិន ជឹម បានអញ្ជើញចូលរួមការដាក់ឱ្យប្រើប្រាស់សាកល្បងដោយឥតគិតថ្លៃ ផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ។
- ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ បានចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពីការស្វែងរកដំណោះស្រាយសម្រាប់ជួសជុលផ្លូវលេខ១៤៣ លេខ១៤៥ និងផ្លូវក្នុងភូមិសាស្ត្រក្រុងច្បារមន ខេត្តកំពង់ស្ពឺ ស្ថិតនៅសាលប្រជុំសាលាខេត្ត។
- ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរបានអញ្ជើញចូលរួមវេទិកាសាធារណៈ ស្ថិតនៅឃុំអូ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

- ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ២០២២ លោក ប៉ាសួង សៅគន្ធ អនុប្រធានមន្ទីរបានអញ្ជើញចូលរួមកិច្ចប្រជុំសាមញ្ញលើកទី៣៧ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្ត តាមប្រព័ន្ធ Zoom។
- ថ្ងៃ ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ២០២២ លោក ប៉ាសួង សៅគន្ធ អនុប្រធានមន្ទីរ និងសហការីបានចូលរួមប្រជុំផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធនិងការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ស្ថិតនៅសាលប្រជុំសាលាខេត្ត អគ្គារ ខ។
- ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ២០២២ លោក អៀង ដាំ ប្រធានមន្ទីរ និងសហការីបានចូលរួមគោរពព្រះវិញ្ញាណក្ខន្ធ ព្រះករុណាព្រះបាទសម្ដេច ព្រះនរោត្តម សីហនុ ស្ថិតនៅខាងមុខសាលាខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ បានចូលរួមក្នុងវេទិកាពិគ្រោះយោបល់កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ២០២៣-២០២៥ ស្ថិតនៅសាលប្រជុំមន្ទីរផែនការខេត្ត។
- ថ្ងៃទី ១៧-២២ ខែ តុលា ឆ្នាំ២០២២ លោក ប៉ាសួង សៅគន្ធ អនុប្រធានមន្ទីរ និងសហការីបានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការបញ្ចូលការបន្សាំ នៃការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ទៅក្នុងផែនការវិនិយោគការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ស្ថិតនៅខេត្តកំពង់ឆ្នាំង។
- ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ បានចូលរួមក្នុងសិក្ខាសាលាសមាហរណកម្ម នៃកម្មវិធីវិនិយោគរបស់ឃុំ សង្កាត់នៅថ្នាក់ ក្រុង ស្រុករបស់ខេត្តកំពង់ស្ពឺស្ថិតនៅស្រុកភ្នំស្រួច។
- ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ បានចូលរួមក្នុងសិក្ខាសាលាសមាហរណកម្ម នៃកម្មវិធីវិនិយោគរបស់ឃុំ សង្កាត់នៅថ្នាក់ ក្រុង ស្រុករបស់ខេត្តកំពង់ស្ពឺ ស្ថិតនៅស្រុកឱរ៉ាល់។
- ថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរបានចូលរួមក្នុងកិច្ចប្រជុំបូកសរុបការអនុវត្តគម្រោង ការស្ម័គ្រចិត្តដើម្បីសាលារៀនខ្ញុំ ស្ថិតនៅសាលប្រជុំបណ្ណាល័យខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ បានចូលរួមប្រជុំបូកសរុបរបាយការណ៍ការងារជំរុញចលនាភូមិមួយផលិតផលមួយ ខេត្តកំពង់ស្ពឺ ស្ថិតនៅសាលប្រជុំគីរីរម្យ នៃមន្ទីរពាណិជ្ជកម្ម។
- ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ២០២២ លោក អៀង ដាំ ប្រធានមន្ទីរ និងលោក ប៉ាសួង សៅគន្ធ អនុប្រធានមន្ទីរ និងសហការី បានចូលរួមក្នុងពិធីប្រកាសទទួលស្គាល់ខេត្តព្រៃវែង ទទួលបានជ័យលាភីខេត្តបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល ស្ថិតនៅខេត្តព្រៃវែង។

- ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ និងលោក ជួប កំសត់ បានចូលរួមកិច្ចប្រជុំស្តីពីផែនការសកម្មភាពការងារអភិវឌ្ឍន៍ជនជាតិភាគតិច ស្ថិតនៅក្រសួងអភិវឌ្ឍន៍ជនបទ។
- ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២ លោក អៀង ដាំ ប្រធានមន្ទីររួមទាំងសហការី បានអញ្ជើញចូលរួមព្រះរាជពិធីបុណ្យខួបលើកទី១៨ នៃការគ្រងព្រះបរមរាជសម្បត្តិរបស់ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅខាងមុខបរិវេណសាលាខេត្ត។
- ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរបានចូលរួមវេទិកាកិច្ចសហប្រតិបត្តិការអន្តរគម្រោង ស្ថិតនៅសាលប្រជុំគិរីរម្យ នៃមន្ទីរពាណិជ្ជកម្មខេត្តកំពង់ស្ពឺ។
- ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ និងលោក លឹម ម៉ាឡែន បានចូលរួមចុះពិនិត្យ និងកំណត់ព្រំប្រទល់ លើខ្នងភ្នំគីរីរម្យ ព្រំប្រទល់រវាងខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ស្ថិតនៅស្នាក់ការកណ្តាលឧទ្យានជាតិគីរីរម្យ។
- ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២២ លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរបានចូលរួមប្រជុំវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ របស់ក្រុមហ៊ុនផលិតថ្មអារ DK Stone Co.LTDនៅមន្ទីរបរិស្ថានខេត្តកំពង់ស្ពឺ។
- ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២២ លោក អៀង ដាំ ប្រធានមន្ទីរ បានចូលរួមក្នុងកិច្ចប្រជុំសាមញ្ញលើកទី៣៨ អាណត្តិទី០៣ របស់ក្រុមប្រឹក្សាខេត្ត តាមរយៈប្រព័ន្ធZOOM។
- ថ្ងៃទី១០-១១ ខែវិច្ឆិកា ឆ្នាំ២០២២ លោក អៀង ដាំ ប្រធានមន្ទីរ និងសហការីបានចូលរួមក្នុងពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៦៩ នៃទិវាបុណ្យឯករាជជាតិ និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ស្ថិតនៅវិមានឯករាជ្យខេត្តកំពង់ស្ពឺ។
- ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២ លោក អៀង ដាំ ប្រធានមន្ទីរបានចូលរួមសិក្ខាសាលាថ្នាក់ជាតិ ផ្សព្វផ្សាយគោលការណ៍ណែនាំស្តីពីការផ្ទៀងផ្ទាត់ស្ថានភាពបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល និងការរៀបចំផែនការបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល ស្ថិតនៅសណ្ឋាគារ កាំបូឌីយ៉ាណា រាជធានីភ្នំពេញ។
- ថ្ងៃទី១៤-១៥ ខែ វិច្ឆិកា ឆ្នាំ២០២២ លោក ចិន ជឹម អនុប្រធានមន្ទីរ និងលោក សាន់ សាមឌី បានចូលរួមវគ្គតម្រង់ទិសស្តីពីសៀវភៅណែនាំអនុវត្តគម្រោង សម្រាប់ក្រុមការងារថ្នាក់ក្រោមជាតិក្នុងខេត្តគោលដៅ នៃគម្រោងបែងចែកដីសង្គមកិច្ច និងការអភិវឌ្ឍន៍សេដ្ឋកិច្ចដំណាក់កាលទី៣ ស្ថិតនៅខេត្តបាត់ដំបង់។
- ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ លោក អៀង ដាំ ប្រធានមន្ទីរ បានចូលរួមក្នុងពិធីបើកការដ្ឋានបោសសម្អាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះកងទ័ពជើងគោក ស្ថិតនៅក្នុងគម្រោងសម្តេចតេជោ សម្រាប់សកម្មភាពមីនស្ថិតនៅ ភូមិគ្រាលបួស ឃុំព្រៃក្មេង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

### ១.២.ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងអប់រំផ្សព្វផ្សាយ ដល់មន្ត្រីរាជការ

#### ១.២.១.ការងារបណ្តុះបណ្តាល និងស្រាវជ្រាវ

- បានចូលរួមសិក្ខាសាលា មានចំនួន ២៧ វគ្គ មន្ត្រីចូលរួម ៥០ នាក់ ស្រី ១១ នាក់ ចំនួន ៦៣ ថ្ងៃនឹង ៥០៤ ម៉ោង។
- វគ្គបណ្តុះបណ្តាល ចំនួន ៣១ វគ្គ មន្ត្រីចូលរួម ៤៧ នាក់ ស្រី ១៣ នាក់ ចំនួន ១៨១ ថ្ងៃស្មើនឹង ១ ៤៤៨ ម៉ោង។

ជាមធ្យមមន្ត្រីរាជការម្នាក់ៗទទួលបានការបណ្តុះបណ្តាល ៤២ ម៉ោង ក្នុងមួយឆ្នាំ បើធៀបនិងផែនការ ៨០ ម៉ោងក្នុងមួយឆ្នាំ។

#### ១.២.២ សកម្មភាពការងារមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទ

មជ្ឈមណ្ឌលអភិវឌ្ឍន៏ជនបទខេត្តកំពង់ស្ពឺ បានបើកវគ្គបណ្តុះបណ្តាលរយៈពេលខ្លី ចាប់ពីខែមករា ដល់ខែធ្នូ ទាំងនៅក្នុង និងក្រៅមជ្ឈមណ្ឌល សំដៅផ្តល់ចំណេះដឹង ជំនាញវិជ្ជាជីវៈជូនប្រជាពលរដ្ឋក្រីក្រតាមជនបទ ឲ្យមានជំនាញបន្ថែមបង្កើនមុខរបរ រកប្រាក់ ចំណូល បង្កើនជីវភាពគ្រួសារ ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ ជូនប្រជាពលរដ្ឋ ទទួលបានលទ្ធផលដូចខាងក្រោមៈ

- បើកវគ្គផ្នែកកសិកម្ម ចិញ្ចឹមសត្វមាន់ ចំនួន ០៥ វគ្គ សិក្ខាកាមសរុប ១០០ នាក់ ស្រី៤០ នាក់។
- បើកវគ្គផ្នែកកសិកម្ម ការដាំបន្លែ ចំនួន ០៥ វគ្គ សិក្ខាកាមសរុប ១០០ នាក់ ស្រី ១៩ នាក់។
- បើកវគ្គផ្នែកកសិកម្ម ការចិញ្ចឹមត្រីចំនួន ០៣ វគ្គ សិក្ខាកាមសរុប ៦០ នាក់ ស្រី ១០ នាក់។
- បើកវគ្គបណ្តុះបណ្តាលជំនាញជួសជុលអណ្តូងស្នប់ ចំនួន ០២ វគ្គ សិក្ខាកាមសរុប ៤០ នាក់ ស្រី១៧ នាក់។

**សរុប ១៥ វគ្គ សិក្ខាកាមចំនួន ៣០០ នាក់ ស្រី ៨៦ នាក់ ស្មើរនិង ១០០% នៃផែនការប្រចាំឆ្នាំ ២០២២។**

### ១.៣.ការងារផែនការ និងស្ថិតិ

- បូកសរុបរបាយការណ៍ប្រចាំ ឆ្នាំ ២០២២ ជូនរដ្ឋបាលខេត្ត និងក្រសួងអភិវឌ្ឍន៍ជនបទ។
- ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយ និងរៀបចំផែនការបីឆ្នាំរំកិល២០២៣-២០២៥របស់រដ្ឋបាលសាលាខេត្ត។
- ថ្ងៃទី២៧ ដល់២៨ ខែមករា ឆ្នាំ២០២២ លោក អ៊ុំ សារឿន បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំគោលការណ៍ណែនាំសមិទ្ធកម្មថវិកាពត៏មានរបស់ក្រសួងអភិវឌ្ឍន៏ជនបទ តាមរយៈអនឡាញ ។
- ថ្ងៃទី០៤-០៥ ខែមេសា ឆ្នាំ២០២២ លោក អ៊ុំ សារឿន ប្រធានការិយាល័យ និងលោក ឃឹន ចាន់ថុល បានចូលរួម សិក្ខាសាលាស្តីពី ការិយាល័យព័ត៍មានឆ្លាតវៃ និងអភិបាលកិច្ច

ល្អក្នុងវិស័យព័ត៌មាន នៅរដ្ឋបាលខេត្តកណ្តាល រៀបចំដោយអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល។

- ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០២២ លោក អ៊ុំ សារឿន ប្រធានការិយាល័យ បានចូលរួមសិក្ខាសាលាស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៣-២០២៥ និងថវិកាសមិទ្ធកម្មឆ្នាំ២០២៣ នៅសណ្ឋាគារសុខា ខេត្តព្រះសីហនុ។
- ចូលរួមត្រួតពិនិត្យ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលមន្ទីរអភិវឌ្ឍន៏ជនបទ បានធ្វើលទ្ធកម្ម និងក្រសួងផ្តល់ជូនមន្ទីរ ។

## ១.៣.ការងារគណនេយ្យនិងហិរញ្ញវត្ថុ

### ១.៣.១.ការគ្រប់គ្រងថវិការដ្ឋ

- រៀបចំឯកសារ ប្រាក់បៀវត្សរ៍ខែ មករា ដល់ ធ្នូ ឆ្នាំ២០២២
- រៀបចំ សៀវភៅសលាប័ត្រតាមដានការប្រើប្រាស់ឥណទាន ឆ្នាំ២០២២
- ទូទាត់ឯកសារ រជ្ជទេយ្យបុរេប្រទាន ជុំទី ១ ដល់ ជុំទី ៤ ឆ្នាំ២០២២។
- ទូទាត់ឯកសារ អណត្តិ អគ្គីសនី ពីខែ ធ្នូ ឆ្នាំ២០២១ ដល់ធ្នូ ឆ្នាំ ២០២២។
- រៀបចំទូទាត់ឯកសារ អណត្តិលទ្ធកម្ម ចំនួន ០៧ គម្រោង ឆ្នាំ ២០២២ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ។
- ទូទាត់ត្រង់ អណត្តិ អគ្គីសនី បេសកកម្ម សម្រាលលំហែមាតុភាព និងការិយាល័យអភិវឌ្ឍន៍សហគមន៍ និងការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ។
- ថ្ងៃទី ២១ ខែមករា ឆ្នាំ២០២២លោក និល មិថុនា ជាអនុប្រធានការិយាល័យ គណនេយ្យ និងហិរញ្ញវត្ថុ ចូលរួមកិច្ចប្រជុំ ផ្សព្វផ្សាយសារាចរណែនាំ ស្តីពីការអនុវត្តច្បាប់ហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ២០២២ នៅសាលប្រជុំមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- ថ្ងៃទី ០៩ ដល់១១ ខែមីនា ឆ្នាំ២០២២ លោក ញ៉ែម ស្រស់ ជាប្រធានការិយាល័យ និង លោក នឹម ប៊ុនថេន កញ្ញា ញឹប ស្រីល័ក្ខ ជាមន្ត្រីការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ ចូលរួមវគ្គបណ្តុះបណ្តាលអំពីគោលការណ៍ណែនាំស្តីពី ការរៀបចំថវិកាសមិទ្ធកម្ម តាមប្រព័ន្ធអនឡាញ Zoom ។
- ថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ ២០២២ លោក និល មិថុនា ជាអនុប្រធានការិយាល័យ គណនេយ្យ និងហិរញ្ញវត្ថុ ចូលរួមសិក្ខាសាលា ស្តីពី ការបំពេញលិខិតប្រកាសពន្ធលើប្រាក់បៀវត្ស នៅសាខាពន្ធដារខេត្តកំពង់ស្ពឺ ។
- ទូទាត់ឯកសារ អណត្តិលទ្ធកម្ម ពិគ្រោះថ្លៃ ចំនួន ០៣គម្រោង៖ ស្តីពីការផ្គត់ផ្គង់កុំព្យូទ័រយួរដៃម៉ាក DELL ០១ គ្រឿង ម៉ាស៊ីនព្រីនធ័រHP2035 ០១ គ្រឿង LOD Projector Optoma ០១ គ្រឿង ការផ្គត់ផ្គង់សម្ភារៈ ការិយាល័យ និងការផ្គត់ផ្គង់ប្រេងឥន្ធនៈ ឆ្នាំ២០២២ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ។
- ថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០២២ លោក ញ៉ែម ស្រស់ ជាប្រធានការិយាល័យ គណនេយ្យ និងហញ្ញវត្ថុ ចូលរួមប្រជុំពិភាក្សាកម្រិតបច្ចេកទេស ស្តីពីការរៀបចំថវិកាសម្រាប់

ការគ្រប់គ្រង ឆ្នាំ ២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាព ឯកឧត្តម ហួត សារឹម អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគារ (គ) ។

- ថ្ងៃទី១៨ ខែវិច្ឆកា ឆ្នាំ ២០២២ លោក ញ៉ែម ស្រស់ ជាប្រធានការិយាល័យ និងលោក នឹម ប៊ុនថេន ជា មន្ត្រី ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ ចូលរួមក្នុងកិច្ចប្រជុំពីភាក្សាអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅសាលប្រជុំសាលាខេត្តអគារ ខ។

**១.៣.២.ការគ្រប់គ្រងសារពើភណ្ឌរបស់មន្ទីរ**

- ឯកសារតារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ស្ពឺ សម្រាប់ ឆ្នាំ២០២១។
- ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២ លោក នឹម ប៊ុនថេន ជាមន្ត្រីការិយាល័យ គណនេយ្យ និងហិរញ្ញវត្ថុ ចូលរួមកិច្ចប្រជុំ ស្តីពីការចុះពិនិត្យផ្ទៀងផ្ទាត់ និងវាយតម្លៃលើការរៀបចំ និងការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ) តារាងកើនឡើងថយចុះទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាម ២០២១ នៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តកំពង់ស្ពឺ។
- គណៈប្រតិភូតអន្តរក្រសួងរវាងក្រសួង អភិវឌ្ឍន៍ជនបទ និងហិរញ្ញវត្ថុ ដឹកនាំ ឯកឧត្តម សួស គង់ចុះពិនិត្យជាក់ស្តែង និងបំពេញនីតិវិធីពាក់ព័ន្ធនឹងសំណើសុំគោលការណ៍អនុញ្ញាតកាត់ដីទំហំ ២៦ម x ៣០ ម ស្មើនឹង ៧៨០ម²ប្រាំពីររយ ប៉ែតសិបម៉ែ) ត្រការដែលស្ថិតនៅក្នុងបរិវេណមន្ទីរអភិវឌ្ឍន៍ជន (បទខេត្តកំពង់ស្ពឺ ជូនក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា។

**១.៣.៣.ការងារសវនកម្ម**

- ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១គណៈប្រតិភូអគ្គាធិការដ្ឋាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះត្រួតពិនិត្យការងាររដ្ឋបាល គណនេយ្យនិងហិរញ្ញវត្ថុ ឆ្នាំ២០២០ ។
- ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០២១ គណៈប្រតិភូត ក្រសួងទំនាក់ទំនងជាមួយ រដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ចុះត្រួតពិនិត្យការងាររដ្ឋបាល និងហិរញ្ញវត្ថុ ឆ្នាំ២០២០ ។
- នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២២គណៈប្រតិភូ អគ្គសវនករ អាជ្ញាធរសាវនកម្មជាតិ ចុះត្រួតពិនិត្យការងាររដ្ឋបាល គណនេយ្យ និងហិរញ្ញវត្ថុ ឆ្នាំ២០២១ ។
- ថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០២២ គណៈ ប្រតិភូនៃអគ្គនាយកដ្ឋានលទ្ធកម្ម នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយដែលបានអនុវត្តរួច និងស្ថិតក្រោមសិទ្ធសម្រេចលើការបរិច្ចេទ ឆ្នាំ២០២១ ។
- គណៈប្រតិភូ អគ្គសវនករ នៃអាជ្ញាធរសាវនកម្មជាតិ អគ្គនាយកដ្ឋានលទ្ធកម្ម នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះត្រួតពិនិត្យ ការងាររដ្ឋបាល ហិរញ្ញវត្ថុ និងការងារលទ្ធកម្ម ឆ្នាំ២០២០។

- គណៈប្រតិភូ អគ្គាធិការកិច្ច នាយកដ្ឋានសវនកម្មផ្ទៃក្នុង អគាធិការកិច្ចក្រសួងហិរញ្ញវត្ថុ អគ្គាធិការដ្ឋាន របស់ក្រសួងអភិវឌ្ឍន៍ជនបទ ចុះត្រួតពិនិត្យការងាររដ្ឋបាល និងហិរញ្ញវត្ថុ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ឆ្នាំ២០២០ ។
- ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចុះធ្វើអធិការកិច្ច ការអនុវត្តតួនាទី-ភារកិច្ច ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈក្នុងកាលបរិច្ឆេទ ឆ្នាំ២០២១ ។

### ១.៣.៤.ការងារលទ្ធកម្ម

- សំណើសុំជានាចំណាយ ចំនួន ០៧ គម្រោង ពិគ្រោះថ្លៃ ០៤ ដេញថ្លៃ ០៣ ក្នុងនោះរួមមាន៖ ពិគ្រោះថ្លៃ ស្តីពីការផ្គត់ផ្គង់កុំព្យូទ័រយួរដៃម៉ាក DELL ០១ គ្រឿង ម៉ាស៊ីនព្រីនធ័រ HP2035 ០១គ្រឿង LOD Projector Optoma ០១ គ្រឿង ការផ្គត់ផ្គង់ សម្ភារៈ ការិយាល័យ ការផ្គត់ផ្គង់ប្រេងឥន្ធនៈ ការងារសាងសង់បង្គន់អនាម័យជូនគ្រួសារក្រីក្រចំនួន ៨០ បង្គន់ ក្នុងស្រុកសរោងទង ចំនួន ៥០បង្គន់ និងស្រុកគងពិសី ៣០ បង្គន់ និងដេញថ្លៃ ស្តីពីការងារសាងសង់អណ្តូង និងតម្លើងស្នប់អាហ្វ្រីដេវ ចំនួន ១៩ អណ្តូង នៅស្រុកសំរោងទង គងពិសី ថ្ពង និងឧដង្គ ការងារជួសជុលផ្លូវក្រាលកំម្ទេចថ្មក្ន៉ំ ចំនួន ០១ ខ្សែ ប្រវែង ៣ ០០០ ម៉ែត្រ ទទឹងខ្នងលើ ៤ ម នៅភូមិត្រពាំងកក់ ឃុំក្រាំងអំពិល ដល់ភូមិព្រៃកំប៉ុក ឃុំធម្មតាអរស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ការងារក្រាលការ៉ូឡា និងជួសជុលដំបូលអគារមន្ទីរ ឆ្នាំ២០២២ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ។
- កំណត់ហេតុបញ្ចប់សុពលភាពចំនួន ០៤ គម្រោង ដេញថ្លៃ ០៣ និងពិគ្រោះថ្លៃ ០១ រួមមាន៖ ការងារដេញថ្លៃ ជួសជុលអណ្តូងស្នប់ ជួសជុលផ្លូវក្រាលកំម្ទេចថ្មក្ន៉ំ និងការងារជួសជុលសាលប្រជុំមន្ទីរ និងពិគ្រោះថ្លៃការងារសាងសង់បង្គន់អនាម័យជូនគ្រួសារក្រីក្រ ជូនក្រុមហ៊ុន ឆ្នាំ២០២១ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ។
- សេចក្តីជូនដំណឹងចំនួន ០៧គម្រោង ពិគ្រោះថ្លៃ០៤ ដេញថ្លៃ០៣។
- បើកឯកសារស្តីពី ការអញ្ជើញចូលរួមពិគ្រោះថ្លៃ និងដេញថ្លៃ ចំនួន ០៧គម្រោង។
- កំណត់ហេតុវាយតម្លៃ ចំនួន ០៧គម្រោង។
- កិច្ចសន្យា ចំនួន ០៧គម្រោង ស្មើនឹង ១០០% នៃផែនការលទ្ធកម្មប្រចាំឆ្នាំ២០២២ ៧ គម្រោង។
- កំណត់ហេតុប្រគល់ទទួល ចំនួន ០៧គម្រោង។

### ១.៤.ការងារយេនឌ័រ

- លោក ប៉ាសួង សៅគន្ធ អនុប្រធានមន្ទីរ និងសហការី បានចូលរួមកិច្ចប្រជុំសាមញ្ញរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ គ ក ស ក នៅសាលាខេត្តកំពង់ស្ពឺ បានចំនួន ១២ លើក ។

- លោកស្រី ណុប ភូមិម៉ាណា បានចូលរួមវេទិកាជាតិដើម្បីស្រ្តី ស្តីពីភាពជាអ្នកដឹកនាំ និង អភិបាលកិច្ចល្អ នៅសាលាកំពង់ស្ពឺ បាន ០១ លើក ស្មើនឹង១០០% សម្រាប់ឆ្នាំ ២០២២។
- លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ បានចូលរួមប្រជុំ ផ្សព្វផ្សាយស្តីពីការលើកកម្ពស់សីលធម៌សង្គមតម្លៃស្រ្តី និងគ្រួសារខ្មែរក្នុងវិស័យ ទេសចរណ៍ នៅសាលាប្រជុំមន្ទីរទេសចណ៍ខេត្តកំពង់ស្ពឺ បានចំនួន ០១ លើក ។
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ បានរៀបចំពិធី សំណេះសំណាល ជាមួយមន្រ្តីដែល ជានារីទាំងអស់នៅមន្ទីរ ចំនួន ១៣ រូប ដើម្បីអបអរសាទរទិវាសិទ្ធនារីអន្តរជាតិ ៨ មីនា លើកទី១១១ ព្រមទាំងមានកាដូសម្រាប់មន្ត្រីជាស្រ្តី ជាសំពត់ហូលម្នាក់ ១ ក្បិន ផងដែរ ដែលសរុបជាទឹកប្រាក់ចំនួន ៣២៥$ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ បានចំនួន ០១ លើក។
- លោក ប៉ាសួង សៅគន្ធ អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ បានរៀបចំពិធី អបអរសាទរខួបអនុស្សាវរីយ៍លើកទី ១១១ ទិវាសិទ្ធនារីអន្តរជាតិ ៨ មីនា ឆ្នាំ ២០២២ នៅស្នាក់ការបក្សឃុំមហាសាំង ខេត្តកំពង់ស្ពឺបានចំនួន ០១ លើក។
- លោកស្រី ណុប ភូមិម៉ាណា បានចូលរួមវេទិកាជាតិដើម្បីស្រ្តី ស្តីពីភាពជាអ្នកដឹកនាំ និង អភិបាលកិច្ចល្អ នៅសាលាកំពង់ស្ពឺ បាន ០១ លើក។
- លោក ប៉ុក ចាន់ថន អនុប្រធានមន្ទីរ និង កញ្ញា ខៀវ សុភី មន្ត្រីរាជការនៃមន្ទីរអភិវឌ្ឍន៍ ជនបទខេត្តកំពង់ស្ពឺ បានចូលរួមប្រជុំ បូកសរុបលទ្ធផលការងារឆ្នាំ ២០២១ និងលើក ទិសដៅបន្តឆ្នាំ ២០២២ របស់សមាគន៍នារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ខេត្ត កំពង់ស្ពឺ នៅសណ្ឋាគារផោមរីវើ ខេត្តកំពង់ស្ពឺ បាន ០១ លើក។
- ថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០២២ លោកស្រី ស៊ុម ដួងដារ៉ា បានចូលរួម ពិធីអបអរ សាទរព្រះរាជពិធីបុណ្យគ្រងរាជសម្បត្តិខួបលើកទី ១៨ ឆ្នាំ របស់ព្រះករុណា ព្រះបាទ សម្តេច ព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរា រដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាសកម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី ក្រោមអធិបតីភាព ឯកឧត្តម យឹម សុខុម ប្រធានក្រុមប្រឹក្សាខេត្ត និងឯកឧត្តម វ៉ី សំណាង អភិបាលនៃគ ណៈអភិបាលខេត្ត នៅមុខសាលាខេត្ត កំពង់ស្ពឺ បានចំនួន ០១ លើក ។
- ថ្ងៃទី ១០-១១ ខែតុលា ឆ្នាំ ២០២២ លោកស្រី ស៊ុម ដួងដារ៉ា លោកស្រី ស៊ុន ស៊ីថា លោកស្រី ផេង ស្រីខួច កញ្ញា ខៀវ សុភី និងកញ្ញា ញឹប ស្រីល័ក្ខ បានចូលរួម ពីធីដាក់ កម្រងផ្កាគោរពវិញ្ញាណក្ខន្ធ ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី ៦៩ នៃទិវាបុណ្យឯក រាជ្យជាតិ និងទិវាកំណើតកងយោធពលខេមរភូមិន្ទ(៩ វិច្ឆិកា ១៩៥៣ - ៩ វិច្ឆិកា ២០ ២២) ខេត្តកំពង់ស្ពឺ បានចំនួន ០១ លើក ។

### ១.៥.ការងារក្រុមប្រឹក្សាសកម្មភាពជនមានពិការភាព

- ថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០២២ លោក ប៉ាសួង សៅគន្ធ អនុប្រធានមន្ទីរ បានចូលរួមប្រជុំប្រចាំត្រីមាសទី២ នៃក្រុមប្រឹក្សាសកម្មភាពជនពិការខេត្តកំពង់ស្ពឺ អនុម័តលើផែនការសកម្មភាពសម្រាប់ឆ្នាំ ២០២២ និងរៀបចំផែនការសកម្មភាព និងថវិកាសម្រាប់ ឆ្នាំ ២០២៣ ។
- លោក ប៉ាសួង សៅគន្ធ បានចូលរួមប្រជុំបូកសរុបការងារ ប្រចាំឆ្នាំ២០២២ ក្រោមអធិបតីភាពលោកជំទាវ ប្រាក់ ថាវការី អគ្គលេខាធិការរង D.A.C និងលោកជំទាវ ឡុង បូណារ៉េត អភិបាលរងខេត្ត និងជាប្រធានក្រុមការងារ D.A.C ខេត្តកំពង់ស្ពឺ។
- បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សម្រាប់ជនពិការភាព នឹងបានបណ្តុះបណ្តាលបន្តដល់មន្ត្រីមន្ទីរ ចំនួន ១២ នាក់ ស្រី ០២ នាក់ ។
- លោកស្រី ស៊ុម ដួងតារា ចូលរួមប្រជុំបូកសរុបលទ្ធផលការងារសមាគមន៍នារីដើម្បីសន្តិភាព និងការអភិវឌ្ឍន៍។

## ២. ការងារអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍

### ២.១. ការងាររៀបចំបញ្ជីសារពើភ័ណ្ឌ និងទិន្នន័យផ្លូវជនបទ

- ក្រុមការងារបានចុះស្រង់ទិន្នន័យផ្លូវថ្មីសម្រាបឆ្នាំ ២០២២ បានចំនួន ១៨ ខ្សែ ប្រវែង ៤៤,៦៩ គ.ម ស្ថិតនៅស្រុកឱរ៉ាល់ ស្រុកសំរោងទង ស្រុកថ្ពង ស្រុកគងពិសី ស្រុកឧដុង្គ ស្រុកភ្នំស្រួច ស្រុកបរសេដ្ឋ និងក្រុងច្បារមន បើធៀបផែនការ ១ ឆ្នាំ ២០២២ ប្រវែង ៣៦,៨០ គ.ម ស្មើនឹង ១២១% នៃផែនការឆ្នាំ ២០២២។
- ធ្វើបច្ចុប្បន្នភាពផ្លូវជនបទ សម្រេចបានចំនួន ៦៤ ខ្សែ ប្រវែង ២០៧,៦៤ គម ស្ថិតនៅក្នុងស្រុកឱរ៉ាល់ ស្រុកសំរោងទង ស្រុកថ្ពង ស្រុកគងពិសី ស្រុកឧដុង្គស្រុក ភ្នំស្រួច ស្រុកបរសេដ្ឋ និងក្រុងច្បារមន ស្មើនឹង ១០០% នៃផែនការឆ្នាំ ២០២២ ។
- រៀបចំបញ្ជីសារពើភ័ណ្ឌ និងមូលដ្ឋានទិន្នន័យផ្លូវជនបទ នៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ ក្រុមការងារបានចុះបញ្ជីផ្លូវជនបទសរុបចំនួន ១ ៣១១ ខ្សែ ប្រវែង ៣០៨០,៥៧ គ.ម។ សរុបសម្រាប់ឆ្នាំ ២០២២ ក្រុមការងារបានចុះបញ្ជីផ្លូវជនបទសរុបចំនួន ១ ៣១២ ខ្សែ ប្រវែង ៣ ០៨៦,៨៧ គ.ម ។

### ២.២. ការងារថែទាំផ្លូវជនបទ និងសំណង់សិល្បការ្យ

- (១.៤.៥.ច.ស.ទី.៥.១) ការងារថែទាំលក្ខណៈខួបបាននឹងកំពង់ដំណើរការសម្រាប់ឆ្នាំ ២០២២ មានចំនួន១ ខ្សែប្រវែង ១២,៤៧ គ.ម អនុវត្តបាន ១០០% នៃផែនការខ្សែផ្លូវនោះគឺៈ ខ្សែផ្លូវទី ១ (ថ្នល់បទ-គង់លើ) ប្រវែង ១២,៤៧ គម ខ្នងលើ ៨ ម កម្រាលក្រួសក្រហម ស្ថិតនៅក្នុងឃុំជំម្ពូព្រឹក ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ។

- (១.៤.៥.ច.ស.ទី.៥.១) ការងារថែទាំលក្ខណៈប្រចាំបាន និងកំពង់ដំណើរការសម្រាប់ឆ្នាំ ២០២២ មានចំនួន ១០ ខ្សែប្រវែង ១២២,២៦ គ.ម អនុវត្តបាន ១០០% នៃផែនការខ្សែផ្លូវទាំងនោះគឺ៖
  - ខ្សែផ្លូវ (ព្រៃឫស្សី-ដុំរទេះ) ឃុំជាំសង្កែ ស្រុកភ្នំស្រួច ៤,៥០ គ.ម ខ្នងលើ ៧ ម កម្រាល ក្រួសក្រហម។
  - ខ្សែផ្លូវ (កុមារពេទ្យ) ឃុំអូរ និងដំបូករូង ស្រុកភ្នំស្រួច ៦,០០ គ.ម ខ្នងលើ ៧ ម កម្រាល ក្រួសក្រហម។
  - ខ្សែផ្លូវ (ចេក-បុស្សក្រឡា)ឃុំអូរនិងព្រៃរំដួល ស្រុកភ្នំស្រួច ៩,០០ គ.ម ខ្នងលើ ៤ ម កម្រាល ក្រួសក្រហម។
  - ខ្សែផ្លូវ (សំបួ-ទឹកថ្លា) ឃុំដំបូករូង ស្រុកភ្នំស្រួច ៧,៥០ គ.ម ខ្នងលើ ៥ ម កម្រាល ក្រួសក្រហម។
  - ខ្សែផ្លូវ(តាសាល-អូរស្បា) ឃុំទំពមាន ស្រុកថ្ពង ១១,៧០ គ.ម ខ្នងលើ ៥ ម កម្រាលល្បាយថ្មភ្នំ។
  - ខ្សែផ្លូវ (បន្ទាយខ្មែរ-ត្រាចកោង -យស់ដោរ) ឃុំជើងរាស់ និងយុទ្ធសាមគ្គី ស្រុកឧដុង្គ ១២,៦៦ គ.ម ខ្នងលើ ៤ ម កម្រាលក្រួសក្រហម។
  - ខ្សែផ្លូវ (តានី-ដុំខ្ចិត-តាំងស្គុក) ឃុំក្រាំងចេក ឃុំយុទ្ធសាមគ្គី និងមានជ័យ ស្រុកឧដុង្គ ប្រវែង ២៣,៧០ គ.ម ខ្នងលើ ៤ ម កម្រាលក្រួសក្រហម។
  - ខ្សែផ្លូវ(ដុំខ្ចិត-កន្ទម)ឃុំវាលពន់ ស្រុកថ្ពងប្រវែង ១៣,៥០ គ.ម ខ្នងលើ ៤ ម កម្រាលក្រួសក្រហម ។
  - ខ្សែផ្លូវ (ត្រពាំងដុះក្រួស-កណ្តាល) ឃុំតាំងសំរោង ស្រុកភ្នំស្រួច ប្រវែង ២៤,០០ គ.ម ខ្នងលើ ៦ ម កម្រាលក្រួសក្រហម។
  - ខ្សែផ្លូវ (ព្រៃក្រសាំង-រលាំងបែង) ឃុំព្រៃក្រសាំង ស្រុកឧដុង្គប្រវែង ៩ ,៧០ គ.ម ខ្នងលើ ៤ ម កម្រាលក្រួសក្រហម។
- (១.៤.៥.ច.ស.ទី.៥.១)ការងារថែទាំលក្ខណៈប្រចាំផ្លូវកៅស៊ូពីរជាន់(DBST)បាននិងកំពង់ដំណើរកាសម្រាប់ឆ្នាំ២០២២មានចំនួន៣ខ្សែប្រវែង ៧០,៧០ គ.ម អនុវត្តបាន ១០០% នៃផែនការខ្សែផ្លូវទាំងនោះគឺ៖
  - ខ្សែផ្លូវ(ក្រាំខ្វាយ-កណ្តាល) ឃុំតាំងស្យានិងតាំងសំរោង ស្រុកភ្នំស្រួច ប្រវែង ១៤,១០ គ.ម ខ្នងលើ ៦ ម កម្រាលកៅស៊ូពីជាន់(DBST)។
  - ខ្សែផ្លូវ (តាឡាត់-កណ្តាល) ឃុំអូរ ឃុំដំបូករូង ឃុំជាំសង្កែ ឃុំព្រៃក្មេងស្រុកភ្នំស្រួច ប្រវែង ២០,១០ គ.ម ខ្នងលើ ៦ ម កម្រាលកៅស៊ូពីជាន់(DBST)។
  - ខ្សែផ្លូវ (ផ្សាស្លាបលែង-សាលា) ឃុំ ស្វាយរំពារ ឃុំកក់ ឃុំផុង ឃុំព្រះខែ ឃុំកាត់ភ្លក់ និងឃុំកក្តី ស្រុកបរសេដ្ឋ ប្រវែង ៣៣,៥០ គ.ម ខ្នងលើ ៥ ម កម្រាលកៅស៊ូពីជាន់(DBST)។

- ការងារជួសជុលផ្លូវល្បាយកម្មិចថ្មកំ្ន ដំណើរការសកម្មភាពសម្រេចបាន ១០០% ផ្លូវស្ថិតនៅឃុំក្រាំអំពិល ស្រុកសំរោងទខេត្តកំពង់ស្ពឺ។ (ត្រពាំងកក់ ដល់ត្រពាំងលាភ) ប្រវែង ៣ ០០០ ម ខ្នងលើ ៥ ម ។

## ២.៣. ការងារអន្តរាគមន៍សង្គ្រោះបន្ទាន់

- (១.៤.៥.ច.ស.ទី.៥.១) ការងារអន្តរាគមន៍បន្ទាន់សម្រាប់ឆ្នាំ ២០២២ បានជួសជុល ៣ ខ្សែប្រវែង ១៣,៤៩០ ម អនុវត្តសម្រេចបាន ១០០% នៃផែនការខ្សែផ្លូវនោះគឺ៖
  - ខ្សែផ្លូវ (អង្គតាប៉ុក-ទឹកឫស្សី) ឃុំជើងរាស់ ស្រុកឧដុង្គ ប្រវែង ៥,៥៩ គ.ម ទទឹង ៥ ម កម្រាល ក្រួសក្រហម។
  - ខ្សែផ្លូវ (កុមារពេទ្យ-ពាមអន្ទង់)ឃុំដំបូករូង ស្រុកភ្នំស្រួច ប្រវែង ២,៩០០ ម ទទឹង ៦ ម កម្រាលក្រួសក្រហម។
  - ខ្សែផ្លូវ (ពាមអន្ទង់-ឈើទាលពក)ឃុំដំបូករូង ស្រុកភ្នំស្រួច ប្រវែង ៥,០០០ ម ទទឹង ៦ ម កម្រាលក្រួសក្រហម។

## ២.៤. ការងារត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់លើផ្លូវជនបទ

សម្រាប់ឆ្នាំ២០២២ ក្រុមការងារចុះត្រួតពិនិត្យយានយន្តបាន៩៦លើកស្មើ១០០% តាមផែនការឆ្នាំ២០២២ និងផ្សព្វផ្សាយខិតបណ្ណរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ស្តីពីការដឹកលើសទម្ងន់កម្រិតកំណត់ និងខុសទំហំរបស់យានយន្ត តាម ច្បាប់ផ្លូវថ្នល់ ដល់អ្នកបើកបរ និងធ្វើការណែនាំនៃការប្រើប្រាស់ផ្លូវ ការដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ថែមទាំងធ្វើការពន្យល់ដល់ពួកគាត់អំពីការផ្ទុកទម្ងន់តាមភ្លៅថយន្តនីមួយៗ របស់យានយន្តធនធំដែលធ្វើចរាចរណ៍ឆ្លងកាត់លើខ្សែផ្លូវជនបទ ក្នុងខេត្តកំពង់ស្ពឺ។

# ៣. ការងារកែសម្អលលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ

## ៣.១. ការងារផ្គត់ផ្គង់ទឹកជនបទ

### ៣.១.១. ការងារសាងសង់អណ្តូងទឹក ប្រភពទឹក និងហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតជនបទចម្រុះ

នៅក្នុងឆ្នាំ ២០២២ សាងសង់អណ្តូងស្នប់សរុបចំនួន ៣៩ អណ្តូងក្នុងនោះ៖

- សាងសង់អណ្តូង និងតម្លើងស្នប់អាហ្វ្រីដេវបានចំនួន ១០ អណ្តូង និងអណ្តូងបំពាក់ម៉ូទ័រ ចំនួន ១០ អណ្តូង សម្រេចបាន ១០០% នៃផែនការប្រចាំឆ្នាំ ២០២២ ដោយប្រើប្រាស់ថវិកាក្រសួងអភិវឌ្ឍន៍ជនបទ ស្ថិតនៅ ស្រុកថ្ពង ២០ អណ្តូង។
- សាងសង់អណ្តូង និងតម្លើងស្នប់អាហ្វ្រីដេវបានចំនួន ១៩ អណ្តូង ដោយប្រើប្រាស់ថវិកាមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ សម្រេចបាន ១០០% នៃផែនការប្រចាំឆ្នាំង ២០២២ ស្ថិតនៅស្រុកគងពិសី ស្រុកសំរោងទង ស្រុកឧដុង្គ ក្រុងច្បារមន និងស្រុកថ្ពង។

### ៣.១.២. ការងារថែទាំ និងជួសជុលអណ្តូងទឹកស្អាតជនបទ

- ស្តាស្រះទឹកសហគមន៍ចំនួន ០១ កន្លែង នៅភូមិអាញ្ញាសេះ ឃុំទព័មាន ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ទំហំ ៥០ម X ៣០ម x ៣ម សម្រេចបានចំនួន ១០០% នៃផែនការ

ប្រចាំឆ្នាំ ២០២២ ដោយប្រើប្រាស់ថវិកាក្រសួងអភិវឌ្ឍន៍ជនបទ។

- ជួសជុលអណ្តូងស្នប់បានចំនួន ១៨៦ អណ្តូង ស្មើនឹង ១០០% នៃផែនការ ១៨៦ អណ្តូង ស្ថិតនៅស្រុកសំរោងទង ៣៦ អណ្តូង ស្រុកឱរ៉ាល់ ១២ អណ្តូង ស្រុកបសេដ្ឋ ១៩ អណ្តូង ស្រុកឧដុង្គ ៤០ អណ្តូង ស្រុកភ្នំស្រួច ៤៦ អណ្តូង និងស្រុកថ្ពង ៣៣ អណ្តូង ដែលគាំទ្រថវិកាដោយគម្រោង(ADB)។

### ៣.១.៣.ការងារស្រង់ គ្រប់គ្រងទិន្នន័យទឹកស្អាតជនបទ

បានធ្វើការប្រមូលទិន្នន័យការងារផ្គត់ផ្គង់ទឹកជនបទ នៅក្នុងស្រុកចំនួន ០៦ ឃុំ ចំនួន ១២ សម្រាប់អនុវត្តន៍កម្មវិធីអភិវឌ្ឍន៍ផ្នែកគោលនយោបាយ(ADB) ក្នុងការជួសជុល និងថែទាំងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ប្រកបដោយនិរន្តភាព មានដូចជា៖ ១.ស្រុកបសេដ្ឋ ឃុំកក់ ស្រុកគងពិសី ឃុំទឹកល្អក់ ស្រុកសំរោងទង ឃុំខ្ទុំក្រាំង ស្រុកឧដុង្គ ឃុំចាន់សែន ស្រុកឱរ៉ាល់ ឃុំរស្មីសាមគ្គី ស្រុកភ្នំស្រួច ឃុំគីរីវ័ន្ត ព្រៃក្មេង ដាំសង្កែ ដំបូករូង តាំងសំរោង ចំបក់ និងឃុំព្រៃវិជ្ជុល។

គិតត្រឹមខែវិច្ឆិកា ឆ្នាំ ២០២២ ក្នុងទូទាំងខេត្តកំពង់ស្ពឺ មានអត្រាគ្របដណ្តប់ទឹកស្អាតប្រើប្រាស់ប្រមាណ ៧៣ %។

**តារាងចំនួនគ្រួសារប្រើប្រាស់ទឹកស្អាត នៅក្នុងខេត្តកំពង់ស្ពឺ**

| ល.រ | ចំនួនស្រុក | ចំនួនគ្រួសារសរុប | ចំនួនមនុស្សសរុប | ចំនួនស្រីសរុប | ចំនួនអណ្តូងស្នប់សរុប | អាងត្រងទឹកភ្លៀង | ស្រះសហគមន៍ | ប្រព័ន្ធចែកចាយទឹកស្អាតខ្នាតតូចសហគមន៍(កន្លែង) | គ្រួសារប្រើប្រាស់ប្រព័ន្ធចែកចាយទឹកស្អាត | ស្ថានីយ៍បន្សុទ្ធទឹកបំពង់ ២០លីត្រ(កន្លែង) | ចំនួនគ្រួសារមានទឹកស្អាតប្រើប្រាស់ | ភាគរយប្រើប្រាស់ទឹកស្អាត % |
|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | បសេដ្ឋ | 33,808 | 150,383 | 77,426 | 1,016 | 590 | 348 | 7 | 1,310 | 2 | 20,806 | 62% |
| 2 | ច្បារមន | 10,127 | 50,336 | 25,526 | 188 | - | 18 | - | 7,367 | - | 9,861 | 97% |
| 3 | គងពិសី | 30,323 | 142,315 | 72,786 | 848 | 303 | 410 | - | 1,762 | - | 21,735 | 72% |
| 4 | ឱរ៉ាល់ | 8,817 | 40,224 | 20,347 | 273 | 16 | 98 | 9 | 37 | - | 5,954 | 68% |
| 5 | ឧដុង្គ | 29,998 | 139,924 | 72,281 | 1,111 | 350 | 335 | 8 | 4,655 | 1 | 23,837 | 79% |
| 6 | ភ្នំស្រួច | 24,896 | 114,180 | 57,397 | 590 | 447 | 151 | 27 | 4,182 | 5 | 15,611 | 63% |
| 7 | សំរោងទង | 37,419 | 172,014 | 88,982 | 1,485 | 558 | 280 | 12 | 8,186 | 5 | 30,114 | 80% |
| 8 | ថ្ពង | 13,990 | 62,745 | 32,175 | 442 | 16 | 91 | 11 | 778 | 1 | 8,049 | 58% |
| **សរុប** | | **189,378** | **872,121** | **446,920** | **5,953** | **2,280** | **1,731** | **74** | **28,277** | **14** | **136,341** | **73%** |

## ៣.២. ការងារថែទាំសុខភាពជនបទ

### ៣.២.១. ការងារសាងសង់បង្គន់អនាម័យជនបទ

- បានចុះត្រួតពិនិត្យការងារសាងសង់បង្គន់ ៥០ ដែលជាអំណោយរបស់ ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង សម្រេចបាន ១០០% ។

- បានផ្តត់ផ្គង់សម្ភារៈបង្គន់អនាម័យជូនគ្រួសារក្រីក្រចំនួន ៨០ ឈុត នៅស្រុកគងពិសី ដែលប្រើប្រាស់ថវិការបស់មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ស្ពឺ ស្មើនឹង ១០០% នៃផែនការ ៨០ ឈុត។ បច្ចុប្បន្នជំរុញប្រជាពលរដ្ឋសាងសង់ផ្ទះបង្គន់បានចំនួន ៨០ បង្គន់។
- បានផ្តត់ផ្គង់សម្ភារៈបង្គន់អនាម័យ ដល់គ្រួសារក្រីក្រ ចំនួន ៥០០ ឈុត នៅស្រុកសំរោងទង និងស្រុកថ្ពង ដែលប្រើប្រាស់ថវិការបស់ក្រសួងអភិវឌ្ឍន៍ជនបទ ស្មើនឹង ១០០% នៃផែនការ ៥០០ ឈុត។ បច្ចុប្បន្នជំរុញប្រជាពលរដ្ឋសាងសង់ផ្ទះបង្គន់បានចំនួន ៥០០ បង្គន់។

### ៣.២.២. ការងារស្រង់ទិន្នន័យបង្គន់អនាម័យជនបទ

នៅទូទាំងខេត្តកំពង់ស្ពឺ គិតមកដល់ខែវិច្ឆិកា ឆ្នាំ ២០២២ មានបង្គន់អនាម័យចំនួនសរុប ១៧៦,២១១ បង្គន់ និងមានអត្រាគ្របដណ្តប់អនាម័យប្រមាណ ៩៦.៣៣%។

**តារាងចំនួនខ្នងផ្ទះមានបង្គន់ប្រើប្រាស់ នៅក្នុងខេត្តកំពង់ស្ពឺ**

| ល.រ | ឈ្មោះ ស្រុក/ក្រុង | ចំនួនខ្នងផ្ទះសរុប | ខ្នងផ្ទះមានបង្គន់ប្រើប្រាស់សរុប | ចំនួនខ្នងផ្ទះប្រើបង្គន់រួម | ចំនួនបង្គន់នៅសល់ | %អនាម័យបច្ចុប្បន្ន | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| 1 | បសេដ្ឋ | 30,611 | 30,611 | | - | 100% | ODF |
| 2 | ច្បារមន | 10,964 | 10,617 | 347 | - | 100% | ODF |
| 3 | គងពិសី | 33,675 | 31,100 | 2,229 | 346 | 98.97% | |
| 4 | ឱរ៉ាល់ | 8,976 | 5,525 | 966 | 2,485 | 72.32% | |
| 5 | ឧដុង្គ | 31,694 | 26,771 | 2,260 | 2,663 | 91.60% | |
| 6 | ភ្នំស្រួច | 25,806 | 23,174 | 1,662 | 970 | 96.24% | |
| 7 | សំរោងទង | 39,902 | 36,336 | 3,071 | 495 | 98.76% | |
| 8 | ថ្ពង | 13,906 | 12,050 | 1,642 | 214 | 98.46% | |
| **សរុប** | | **195,534** | **176,211** | **12,150** | **7,173** | **96.33%** | |

### ៣.២.៣. ការងារលើកកម្ពស់ ការផ្លាស់ប្តូរទម្លាប់ ឲ្យមានការរស់នៅស្អាតនិងមានអនាម័យនៅជនបទ

- មន្ទីរបានធ្វើកិច្ចសហការជាមួយអង្គការយូនីសេហ្វ(UNICEF/ Water Aid) បានចុះអនុវត្តកម្មវិធី CLTS ក្រុងច្បារមនស្រុកឧដុង្គ ស្រុកថ្ពង ស្រុកគងពិសី ស្រុកឱរ៉ាល់ និងស្រុកសំរោងទង។
- សហការជាមួយគម្រោង កម្មវិធីអភិវឌ្ឍន៍ផ្នែកសេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទដំហានទី ៣ ក្រោមហិរញ្ញប្បទានរបស់ធនាគាអភិវឌ្ឍន៍អាស៊ី )ADB) អនុវត្តនៅស្រុកភ្នំស្រួច។

## ៤. ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ

### ៤.១. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

#### ៤.១.១. ការងារលើកកម្ពស់ការបង្កើតការងារ និងមុខរបរនៅជនបទ

- បានចុះត្រួតពិនិត្យ ការងារឥណទានក្រុម នៅភូមិព្រៃមិច ១ ឃុំវាលពន់ ស្រុកថ្ពង ចំនួន ១២ លើក

- ចុះប្រមូលប្រាក់ពីសមាជិកឥណទានក្រុមនៅភូមិព្រៃមិច ១ ឃុំវាលពន់ស្រុកថ្កូង ចំនួន ១២ លើក ដែលមានទឹកប្រាក់ចំនួន ១៩,១៦០,៤០០៛ ។
- ចងក្រងក្រុម និងផ្តល់ទុនដល់អតិថិជនឥណទានក្រុម សរុបចំនួន ៣០ នាក់ ស្រី ២៧ នាក់ ។

**ប្រមូលឥណទានក្រុមអនុវត្តន៍បាន ចំនួន ១០០% ធៀបនឹង ១២ លើក នៃផែនការប្រចាំឆ្នាំ ២០២២**

សរុបមកដល់ពេលនេះ (ត្រឹមថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០២២)ទឹកប្រាក់សរុបមាន ១៩,១៦០,៤០០៛ ក្នុងនោះឥណទានក្នុងដៃសមាជិកឥណទានក្រុមមានចំនួន ១៧,០៦៦,២០០៛ និងប្រាក់ក្នុងបេឡាចំនួន ២,០៩៤,២០០៛ អនុវត្តនៅភូមិព្រៃមិច ១ ចំនួន ១២ វគ្គ ស្មើ ១០ ក្រុម មានសមាជិកសរុបចំនួន ៣០ នាក់ស្រី ២៧ នាក់។

### ៤.២. ការងារអភិវឌ្ឍន៍សហគមន៍

#### ៤.២.១. ការងារពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ)

- ចុះធ្វើបច្ចុប្បន្នភាព (គ.អ.ភ) ២ ស្រុក ៨ ឃុំ ស្មើនឹងភូមិចំនួន ១១៣ ភូមិ អនុវត្តបាន ១០០% នៃផែនការ ប្រចាំឆ្នាំ ២០២២ ស្មើនឹង គ.អ.ភ ចំនួន ៩០៤ នាក់ ស្រី ២៧១ នាក់ ដែលមានអ្នកចូលរួមសរុបចំនួន ៧៩១ នាក់ ស្រី ៤៣៥ នាក់ មានអ្នកលាលែងពីការងារចំនួន ៤៩ នាក់ ស្រី ៣៨ នាក់ ដែលត្រូវរើសបន្ថែមមានចំនួនសរុប ៤៩ នាក់។
- បើកវគ្គបណ្តុះបណ្តាល ពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៏ភូមិ(គ.អ.ភ)នៅស្រុកបសេដ្ឋបានចំនួន ៦ វគ្គ អនុវត្តន៍បាន ១០០% នៃផែនការប្រចាំឆ្នាំ ២០២២ ដែលគ្រោង ៦ វគ្គ ស្ថិតនៅឃុំកាត់ភ្លុក ១២ ភូមិ ឃុំកក្តី ១៥ ភូមិ និងឃុំពោធិអង្ក្រង ១៩ ភូមិ ដែលមាន អ្នកចូលរួមសរុប ២១០ នាក់ ស្រី ៩២ នាក់។

#### ៤.២.២. ការងារអភិវឌ្ឍន៍ចម្រុះ

- ចុះត្រួតពិនិត្យសកម្មភាពចិញ្ចឹមមាន់ចំនួន ៣០ គ្រួសារ នៅភូមិព្រៃមិច ១ និងបានពង្រីកសមាជិកថ្មី បានចំនួន ២ គ្រួសារ។
- ចុះត្រួតពិនិត្យគ្រួសារដែលផ្តល់កូនឈើហូបផ្លែចំនួន ៧០ គ្រួសារ នៅភូមិត្រោកវែង ឃុំសែនដី ស្រុកសំរោងទង ជាលទ្ធផលកូនខ្នុរចំនួន ២១០ ដើម និងកូនស្វាយចំនួន ១៤០ ដើមកំពុងតែរីកលូតលាស់បានល្អ។
- ចុះពិនិត្យសកម្មភាព ការងារអភិវឌ្ឍន៍ចម្រុះ នៅភូមិទេវាមានជ័យ និងភូមិព្រៃមិច ១ ឃុំវាលពន់ ស្រុកថ្កូង ជាលទ្ធផល ប្រជាពលរដ្ឋចំនួន ២០ គ្រួសារ បានធ្វើរោងជីកំប៉ុស្ត និងដាំបន្លែគ្រួសារ។
- ចុះត្រួតពិនិត្យគ្រួសារដែលផ្តល់កូនឈើហូបផ្លែចំនួន ៧០ គ្រួសារ នៅភូមិត្រោកវែង ឃុំសែនដី ស្រុកសំរោងទង ជាលទ្ធផលកូនខ្នុរចំនួន ២១០ ដើម និងកូនស្វាយចំនួន ១៤០ ដើម កំពុងតែរីកលូតលាស់បានល្អ បានពង្រីកគ្រួសារចិញ្ចឹមមាន់បានចំនួន ៥ គ្រួសារ លើគ្រួសារចំនួន ៣០ ដែលបាន ផ្តល់ពូជមាន់កាលពីឆ្នាំ ២០១៧ ។

#### ៤.២.៣. ការងារសន្តិសុខស្បៀង

- បានចុះចែកគ្រាប់ពូជបន្លែចម្រុះ ដល់គ្រួសារកសិករចំនួន ១៤០ គ្រួសារ នៅភូមិរំដួលខាងជើង រំដួលខាងកើត និងភូមិចាស់ ស្រុកបសេដ្ឋ និងភូមិស្រែកិន ឃុំត្រពាំងជោរ ស្រុកឱរ៉ាល់។ ក្នុងពូជបន្លែទាំងនោះរួមមាន៖ គ្រាប់ត្រកួន ៨៩០ កញ្ចប់ គ្រាប់ផ្ទីដូង ៤២០ កញ្ចប់ គ្រាប់ស្ពៃ ២៨០ កញ្ចប់ គ្រាប់ត្រសក់ ២៨០ កញ្ចប់ ។

- ចុះត្រួតពិនិត្យសកម្មភាពធ្វើជីកំប៉ុស្ដិ៍ និងជំរុញការដាំដំណាំតាមគ្រួសារ ក្នុងនោះ ភូមិបូរីម្យ ឃុំវាលពង់ ស្រុកឧដុង្គ ចំនួន ២០ គ្រួសារភូមិ អូក្រសារ ភូមិព្រៃមិច និងភូមិគន្ធាំ ឃុំវាលពន់ ស្រុកថ្ពង ចំនួន ៦០ គ្រួសារ។
- ចុះត្រួតពិនិត្យការដាំដំណាំតាមគ្រួសារ ក្នុងនៅ ភូមិ អូក្រសារ ភូមិព្រៃមិច ១ និងភូមិគន្ធាំ ឃុំវាលពន់ ស្រុកថ្ពង ប្រជាពលរដ្ឋចំនួន ៤៥ គ្រួសារមានសួនដំណាំ។

**៤.៣. ការងារអភិវឌ្ឍន៍ និងអភិរក្សជនជាតិភាគតិច**

បានចុះធ្វើបច្ចុប្បន្នភាពទិន្នន័យ ជនជាតិភាគតិចសួយ ក្នុងឆ្នាំ ២០២២ នៅភូមិ គោលដៅចំនួន ០៩ ភូមិ ដែលមាន ៥៧៥ គ្រួសារ ខ្នងផ្ទះសរុប ៥៦៧ ខ្នង ប្រជាជនសរុប ២ ៥១១ នាក់ ស្រី ១ ២៤៤ នាក់ ។

គិតត្រឹមថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០២២ ការិយាល័យអភិវឌ្ឍន៍ជនជាតិភាគតិច អនុវត្ត សកម្មភាពសម្រេចលទ្ធផលបានចំនួន ១០០% នៃផែនការ ឆ្នាំ២០២២ ចំនួន ០៩ ភូមិ ។

**៥. សមិទ្ធិផលនៃការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការ**

**៥.១. គម្រោងកែលម្អផ្លូវជនបទ ក្រាលកៅស៊ូពីរជាន់ RRIP-2 DBST( ADB)**

**ក. គម្រោងកែលម្អផ្លូវជនបទជំហានទី២ RRIP-2**

គម្រោងកែលម្អផ្លូវជនបទជំហានទី ២ RRIP-2 ដែលជាគម្រោងក្រាលកៅស៊ូពីរជាន់ DBST មានចំនួន ០៥ ខ្សែ មានប្រវែង ៥៦,៧០ គ.ម គម្រោងបន្តរយៈពេល ២ ឆ្នាំ (២០២១-២០២២)ដូចខាងក្រោម៖

| ល.រ | ឈ្មោះផ្លូវ | ស្រុក | ឃុំ | ទីតាំង | | ប្រវែង | កម្រាល | លទ្ធផលសម្រេចបាន% |
|---|---|---|---|---|---|---|---|---|
| | | | | ចាប់ផ្ដើម | បញ្ចប់ | គ.ម | | |
| 1 | KSP3 | ភ្នំស្រួច -សំពោងទង | មហាសាំង-ធម្មតាអរ-ព្រៃក្មេង | ត្រពាំងឱប | ប្រិយ៍ | 11.30 | DBST | 100% |
| 2 | KSP7 | បសេដ្ឋ | កក្តី | សហគមន៍លិច | កក្តី | 4,70 | DBST | 100% |
| 3 | KSP8 | សំពោងទង - ឧដុង្គ | សំបូរ-ក្រាំងចេក | អំពិលទឹក | ក្រាំងចេក | 17.80 | DBST | 100% |
| 4 | KSP9 | សំពោងទង - គងពិសី | សែនដី-ពេជ្រមន្ទី | សំពោងជើងភ្នំ | ត្រពាំងស្នួល | 5.90 | DBST | 100% |
| 5 | KSP10 | ថ្ពង -ឧដុង្គ | រុងរឿង-ក្រាំងចេក | ថ្មី | រុងរឿង | 17.00 | DBST | 100% |
| សរុប | | | | | | **56.70** | | |

**ខ. គម្រោងកែលម្អផ្លូវជនបទជំហានទី ៣ RRIP-3**

គម្រោងកែលម្អផ្លូវជនបទជំហានទី៣ ដែលជាគម្រោងក្រាលកៅស៊ូពីរជាន់ DBST RRIP-3 មានចំនួន ០៦ ខ្សែ មានប្រវែង ៨១៩៩, គម គម្រោងបន្តរយៈពេល. ៥ ឆ្នាំ ២០២១)-២០២៥( ដូចខាងក្រោម៖

| ល.រ | ផ្លូវលេខ | ឈ្មោះផ្លូវ | ឈ្មោះឃុំ | ឈ្មោះស្រុក | ប្រវែងផ្លូវ (គម) | កម្រាល | លទ្ធផលសម្រេចបាន% |
|---|---|---|---|---|---|---|---|
| 1 | KSP1 | អូរសំចត - ដក់ពរ | ចំបក់-ក្រាំងដីវ៉ាយ | ភ្នំស្រួច | 20.94 | DBST | 30% |
| 2 | KSP2 | ព្រៃមាន- ក្រាំងធំ | រស្មីសាមគ្គី-តាំងសំរោង | ឱរ៉ាល់-ភ្នំស្រួច | 25.91 | DBST | 10% |
| 3 | KSP3 | ប្រៃយ៍ - កណ្តាល | ក្រាំងដីវ៉ាយ-តាំងសំរោង | ភ្នំស្រួច | 11.56 | DBST | 10% |
| 4 | KSP4 | ដំណាក់ត្រាច - ត្រពាំងទទឹម | ដំបូករូង | ភ្នំស្រួច | 10.46 | DBST | 30% |
| 5 | KSP5 | វាល -ស្វាយជង្គំ | រលាំងចក-ស្គុះ | សំរោងទង | 6.19 | DBST | 5% |
| 6 | KSP7 | ចំប៉ី - វល្លិ៍ប្រេង | តាំងក្រូច -កាហែង | សំរោងទង | 6.93 | DBST | 5% |
| សរុប | | | | | 81.99 | | |

**៥.២. គម្រោងសាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ (CfWRDLEP)**

- ការងារគម្រោងសាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ (CfWRDLEP)សម្រាប់ឆ្នាំ ២០២២ មានចំនួន ៣ ខ្សែប្រវែង ៨,៦៥ គ.ម អនុវត្តបាន ១០០% នៃផែនការខ្សែផ្លូវនោះគឺៈ
  - ខ្សែផ្លូវ (បសេដ្ឋ-បឹងស្កុក-កន្លង់) ឃុំបសេដ្ឋ ស្រុកបសេដ្ឋ ប្រវែង ៣ គ.ម ខ្នងលើ ៥ ម កម្រាល ក្រួសក្រហម។
  - ខ្សែផ្លូវ (កាត់ភ្លុក-រកាធំ) ឃុំកាត់ភ្លុក ស្រុកបសេដ្ឋ ប្រវែង ១,៨០ គ.ម ខ្នងលើ ៥ ម កម្រាល ក្រួសក្រហម។
  - ខ្សែផ្លូវ (កាត់ភ្លុក-រកាកោង) ឃុំកាត់ភ្លុក ស្រុកបសេដ្ឋ ប្រវែង ៣,៨៥ គ.ម ខ្នងលើ ៥ម កម្រាល ក្រួសក្រហម។

**៥.៣. គម្រោងអភិវឌ្ឍន៍ជនបទដោយប្រើប្រាស់វិធីសាស្ត្រចលនាភូមិថ្មី (SMU)**

**កំពុងអនុវត្ត ៤ ស្រុក ក្រុង និង ៤ ឃុំ សង្កាត់ ស្មើនិងចនួន ១០ ភូមិ ៖**

- ក្រុងច្បារមនសង្កាត់ច្បារមន មានចំនួន ០២ ភូមិផ្គង់ និងភូមិត្រពាំងលើក(ការងារប្រព័ន្ធផ្គត់ផ្គង់ទឹក)។
- ស្រុកថ្ពងឃុំវាលពន់ មានចំនួន ០៣ ភូមិអូរក្រេសារ,ភូមិព្រៃមិច ,ភូមិកន្ទាំ(ការងារប្រព័ន្ធផ្គត់ផ្គង់ទឹក)។
- ស្រុកឧដុង្គឃុំវាលពង់មានចំនួន ០៣ ភូមិសូរវង្សលើ និងភូមិបូរីរម្យ (ការងារប្រព័ន្ធផ្គត់ផ្គង់ទឹក)។
- ស្រុកសំរោងទង ឃុំសែនដី មានចំនួន ០៣ ភូមិត្រពាំងប្រីយ៍ភូមិត្រោកវែង និងភូមិព្រៃរំដួល។

❖ **សកម្មភាពសហគមន៍**

- គណៈកម្មការគ្រប់គ្រង និងដឹកនាំគម្រោងតាមភូមិបានចុះត្រួតពិនិត្យការចិញ្ចឹមមាន់ការចិញ្ចឹមជ្រូកការងារប្រព័ន្ធផ្គត់ផ្គង់ទឹកនិងប្រមូលការប្រាក់ឥណទានពីសមាជិកអនុវត្តគម្រោង ។
- ការចិញ្ចឹមមាន់ ៖ ក្នុងខែនេះកូនមាន់កើតបានចំនួន ៦,៣០៣ ក្បាល មាន់លក់អស់ចំនួន៣,៣៦៣ក្បាលបានប្រាក់ចំនួន ៥៤.០៤៦.០០០ រៀល មាន់ធ្វើម្ហូបអស់ចំនួន ២,៤៧៦ ក្បាល មាន់ងាប់ចំនួន ២,៦១៧ ក្បាល មាន់នៅសល់សរុបក្នុងខែមានចំនួន ១៤,៦៤៣ ក្បាល។
- ការងារចិញ្ចឹមជ្រូកៈ ក្នុងឆ្នាំនេះជ្រូកកើតបាន ៣៦ ក្បាល ជ្រូកងាប់អស ១៨ ក្បាល ទិញកូនចូលចំនួន ០ ក្បាល លក់អស់ចំនួន ៦៤ ក្បាល បានប្រាក់ចំនួន ៧៨.០១៩.០០០៛ ជ្រូកនៅសល់សរុបចំនួន ១១៩០ ក្បាល។
- ការងារឥណទានៈ បានប្រមូលការប្រាក់ក្នុងខែនេះបានចំនួនសរុប ២៥០.១៦៨, ដុល្លារ បូកយោងខែមុនសរុបចំនួន ៧ ៥០.៣៨៦,ដុល្លារ។
- ឥណទានដីៈ សមាជិកទិញដីចូលចំនួន ១ ៨២៤ បាវ សមាជិកខ្ចីសរុបចំនួន ៤៦៣ បាវ សមាជិកសងវិញ ចំនួន ១៧៦ បាវ លក់ដីបាន ៨៨ បាវ និងក្នុងឃ្លាំងសល់ដីសរុប ចំនួន ១,៨២៤ បាវ។
- ធនាគារអង្ករៈ ទិញអង្ករចូលសរុបចំនួន ១០ បាវ ប្រជាជនខ្ចី ចំនួន ៨ បាវ និងអង្ករនៅក្នុងឃ្លាំងចំនួន ២ បាវ។
- ការងារប្រព័ន្ធផ្គត់ផ្គង់ទឹកៈ ថវិកាប្រមូលបានក្នុងខែបានចំនួនសរុបចំនួន ៧,៣៦៥ ដុល្លារ ចំណាយប្រតិបត្តិការអស់ចំនួន ៦,៤៦៤ ដុល្លារ សន្សំទុកសរុបចំនួន ៩០១ ដុល្លារ បូកយោង ៥,១៨២ ដុល្លារ។

### ៥.៤ .គម្រោងបែងចែកដីសង្គមកិច្ច និងការអភិវឌ្ឍន៍សេដ្ឋកិច្ច ជំហាន២ (LASED II)

ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ២០២២ លោក ចិន ដឹម អនុប្រធានមន្ទីរ បានចូលរួមដំណើរទស្សនៈកិច្ចជាមួយតំណាងធនាគារពិភពលោកទៅកាន់ទីតាំងដីសម្បទានសង្គមកិច្ចគម្រោង LASED II ស្ថិតនៅភូមិព្រៃធំ ឃុំស្មើសាមគ្គី ស្រុកឪរ៉ាល់។

### ៥.៥. កិច្ចសហការជាអង្គការយូនីសេហ្វ (UNICEF/Water Aid)

- បានបូកសរុបរបាយការណ៍រីកចំរើនបង្គន់អនាម័យប្រចាំខែ ត្រីមាស និងឆ្នាំ របស់ស្រុកគោលដៅទាំង៥ ដូចជាៈនៅស្រុកឧដុង្គ ថ្ពង គងពិសី ឪរ៉ាល់ និងស្រុកសំរោងទង។ ផ្ញើជូនក្រសួងអភិវឌ្ឍន៍ជនបទ និងអង្គការយូនីសេហ្វ ។
- ក្រុមការងារបានចុះត្រួតពិនិត្យ លទ្ធផលការងារជំរុញការសាងសង់បង្គន់ និងការធ្វើបច្ចុប្បន្នភាពទិន្នន័យរបស់ស្រុកគោលដៅ នៃការអនុវត្តកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ឆ្នាំ២០២១ នឹងឆ្នាំ២០២២។

### ៥.៦. កិច្ចសហការជាមួយគម្រោងកម្មវិធីអភិវឌ្ឍន៍ផ្នែកសេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទជំហានទី ៣ ក្រោមហិរញ្ញប្បទានរបស់ធនាគាអភិវឌ្ឍន៍អាស៊ី (ADB) កញ្ចប់ទី ២ នៅក្នុងឃុំដំបូករូង ស្រុកភ្នំស្រួច

ស្តារស្រះទឹកសហគមន៍បានចំនួន ០៣ កន្លែង នៃផែនការឆ្នាំ ២០២១ ០៣ កន្លែង សម្រេចបាន ១០០% នៅក្នុងឃុំជំបូករូង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ មានដូចខាងក្រោម៖

- ភូមិដំណាក់ត្រាច់ ជីកស្តាស្រះទឹកទំហំ ៥៣ម x ៥០ម ជំរៅ ៦ម សម្រេចបាន ១០០%
- ភូមិជំបូករូង ជីកស្តាស្រះទឹកទំហំ ៥០ម x ៣៥ម ជំរៅ ៦ម សម្រេចបាន ១០០%
- ភូមិមានជ័យ ជីកស្តាស្រះទឹកទំហំ ៧០ម x ៥០ម ជំរៅ ៦ម សម្រេចបាន ១០០%

**កញ្ចប់ទី ៣ នៅក្នុងឃុំជាំសង្កែ ស្រុកភ្នំស្រួច**

- សាងសង់អណ្តូងស្នប់សរុបបានចំនួន ០៦ អណ្តូង ស្មើនិង ១០០% នៃផែនការ ក្នុងនោះនៅភូមិស្មើសាមគ្គី ០៥ អណ្តូង និងសលាបឋមសិក្សាភ្នំជៀស ចំនួន ០១ អណ្តូង ឃុំជាំសង្កែ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។
- សាងសង់ពាងសរុបបានចំនួន ២.១៦៣ ពាង ចែកជូនប្រជាពលរដ្ឋ ស្មើនិង ១០០% នៃផែនការ ២,១៦៣ ពាង ក្នុងឃុំជាំសង្កែ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។
- សាងសង់ប្រពន្ធ័ចែកចាយទឹកសហគមន៏ចំនួន ០៣ កន្លែង នៅភូមិព្រៃឬស្សី បានចំនួន ១០០% ភូមិថ្មី បានចំនួន ១០០% និងភូមិដូង បានចំនួន ១០០% ឃុំជាំសង្កែ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

**៥.៧. គម្រោងនិរន្តរភាពតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិកម្ពុជា ( CSLEP)**

ចុះសិក្សាស្ថានភាព និងលើកផែនការសម្រាប់សាងសង់ផ្លូវក្រាលកៅស៊ូពីរជាន់ចំនួន៣ខ្សែ ដូចខាងក្រោម៖

- ខ្សែទី ១ ផ្សារកន្ទួតដល់តាំងបំពង់ ប្រវែង ៣៥ គ.ម( ខ្នងផ្សារ )
- ខ្សែទី ២ ផ្សារព្រៃផ្តៅដល់ស្រែកិនប្រវែង ២៦ គ.ម( ជើងភ្នំឱរ៉ាល់ )
- ខ្សែទី ៣ គោក ដល់តាំងសំរោង ប្រវែង ១៧ គ.ម( ទឹកធ្លាក់ជ្រៀវ )

**៥.៨ .គម្រោងពិពិធកម្មកសិកម្មនៅកម្ពុជា**

ចុះសិក្សាស្ថានភាព និងលើកផែនការសម្រាប់សាងសង់ផ្លូវក្រាលក្រួសក្រហមចំនួន៤ខ្សែ ដូចខាងក្រោម៖

- ខ្សែទី ១ សហគមន៍ឃុំអមលាំង ប្រវែង ១០ គ.ម
- ខ្សែទី ២ សហគមន៍ឃុំគីរីវ័ន្ត ប្រវែង ២ គ.ម
- ខ្សែទី ៣ សហគមន៍ឃុំច្បារមន ប្រវែង ៩ គ.ម

**៥.៩. អង្គការអភិវឌ្ឍន៍ហូឡង់គី SNV**

ចូលរួមផ្សព្វផ្សាយគម្រោងភូមិគ្មានផ្សែង នៅឃុំព្រះខែ ឃុំកក់ ស្រុកបសេដ្ឋ មានអ្នកចូលរួមចំនួន ៤៦ នាក់ ស្រី ២០ នាក់។

**៥.១០. អង្គការទស្សនៈពិភពលោក**

ថ្ងៃទី ២៨ ខែតុលាឆ្នាំ ២០២២ លោក ឆែម សារិទ្ធ អនុប្រធានការិ.ថែទាំសុខភាពជនបទ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ប្រព័ន្ធតាមដានការអនុវត្តគម្រោងទឹកស្អាត និងអនាម័យ (mwater) ដល់បុគ្គលិកអង្គការទស្សនៈពិភពលោកអន្តរជាតិ ដែលទទួលបន្ទុកទឹកស្អាត និងអនាម័យ នៅស្នាក់កណ្តាលអង្គការទស្សនៈពិភពលោកអន្តរជាតិ រាជធានីភ្នំពេញ។

**៥.១១. អង្គការទឹកស្អាត ១០០១**

បច្ចុប្បន្នមានស្ថានីផលិតទឹកពិសាបរិសុទ្ធ អូរី សម្រាប់ផ្គត់ផ្គង់ក្នុងខេត្តកំពង់ស្ពឺ ចំនួន ១៩ ទីតាំង នៃ ១៧ ឃុំ និង ៧ ស្រុក ក្នុងនោះមាន៖ ស្រុកសំរោងទង បសេដ្ឋ ឱរ៉ាល់ ឧដុង្គ ថ្ពង ភ្នំស្រួច និងស្រុកពិសី(**ស្ថានីផលិតទឹក មានចំនួន ៤ទីតាំង អសកម្ម**)។

**៥.១២. កិច្ចសហការជាមួយគម្រោងជំនួយផ្អែកលើលទ្ធផលអនាម័យសម្រាប់ស្ត្រី** (WOBA)

- ថ្ងៃទី ០២ ខែមីនា ឆ្នាំ២០២២ លោក ឆែម សារិទ្ធ អនុប្រធានការិយាល័យថែទាំសុខភាពជនបទ បានចូលរួមជាមួយក្រុមការងារអង្គការ EMW ចុះពិនិត្យស្ថានភាពពីការសាងសង់បង្គន់ និងការប្រើប្រាស់បង្គន់ របស់ប្រជាពលរដ្ឋ របស់គម្រោង WOBA2 នៅឃុំព្រៃក្មេង ស្រុកភ្នំស្រួច និងឃុំស្វាយចចឹប ស្រុកបសេដ្ឋ។
- ថ្ងៃទី ១៧-១៨ ខែមីនា ឆ្នាំ២០២២ លោក ឆែម សារិទ្ធ បានចូលសិក្ខាសាលាស្តីពីការចែករំលែក និងផ្លាស់ប្តូរបទពិសោធន៍ការអនុវត្តកម្មវិធី WOBA របស់អងង្គការ EMW តាមប្រព័ន្ធអនឡាញ ZOOM Meeting។
- ថ្ងៃទី ១០-១២ ខែវិច្ឆិកា ឆ្នាំ ២០២២ លោក ឆែម សារិទ្ធ អនុប្រធានការិ.ថែទាំសុខភាពជនបទ បានចូលរួមវគ្គសិក្ខាសាលា ចែករម្លែកបទពិសោធន៍ស្តីពី ការរៀបចំផែនការសុវត្ថិភាពទឹក ក្នុងតំបន់បម្រែបម្រួលអាកាសធាតុ នៅសង្កាត់ខចំរើនផល ក្រុងពោធិសាត់ ។

**៥.១៣. អង្គការ** ARD

ចូលរួមប្រជុំជាមួយអង្គការ ARD ពិភាក្សាទៅលើលក្ខន្តិក និងលិខិតស្នើសុំទទួលស្គាល់ ប្រពន្ធ័ចែកចាយទឹកសហគមន៍ នៅតាមឃុំគោលដៅរបស់គម្រោង និងផែនការដែលត្រូវអនុវត្ត នៅក្នុងខេត្តកំពង់ស្ពឺ។

**៥.១៤. អង្គការជីវិតថ្លៃថ្នូរ** (LWD)

- ថ្ងៃទី ២០-២២ ខែធ្នូ ឆ្នាំ ២០២១ លោក រស់ សុផល និងលោក ឆែម សារិទ្ធ បានចូលរួមសម្របសម្រួលវគ្គបណ្តុះបណ្តាលស្តីពី សហគមន៍ដឹកនាំអនុវត្តអនាម័យ (CLTS) ដល់ជនបង្គោលអនាម័យភូមិ ចំនួន ២ ឃុំ នៅស្រុកឱរ៉ាល់ ដែលរៀបចំដោយអង្គការជីវិតថ្លៃថ្នូ (LWD) នៅសាលប្រជុំរដ្ឋបាលស្រុក ស្រុកឱរ៉ាល់។
- ថ្ងៃទី២៦-២៨ ខែមករា ឆ្នាំ ២០២២ លោក រស់ សុផល និងលោក ឆែម សារិទ្ធ បានចូលរួមសម្របសម្រួលវគ្គបណ្តុះបណ្តាលស្តីពី ផែនការសុវត្ថិភាពទឹក ដល់ជនបង្គោលទឹកស្អាត និងអនាម័យឃុំ និងភូមិ មកពីឃុំត្រពាំងជោ នៅស្រុកឱរ៉ាល់ ដែលរៀបចំដោយអង្គការជីវិតថ្លៃថ្នូ (LWD) នៅសាលប្រជុំសាលាស្រុកឱរ៉ាល់។
- ថ្ងៃទី ០៨-១០ ខែកុម្ភៈ ឆ្នាំ ២០២២ លោក រស់ សុផល និងលោក ឆែម សារិទ្ធ បានចូលរួមសម្របសម្រួលវគ្គបណ្តុះបណ្តាលស្តីពី ផែនការសុវត្ថិភាពទឹក ដល់ជនបង្គោលទឹកស្អាត និងអនាម័យឃុំ និងភូមិ មកពីឃុំចំនួន នៅស្រុកភ្នំស្រួច ដែលរៀបចំដោយអង្គការជីវិតថ្លៃថ្នូ (LWD) នៅស្នាក់ការអង្គការជីវិតថ្លៃថ្នូរ (LWD) នៅភូមិបេង ឃុំចំបក់ ស្រុកភ្នំស្រួច។
- ថ្ងៃទី ០៩-១០ ខែមីនា ឆ្នាំ ២០២២ លោក រស់ សុផល បានចូលរួមសម្របសម្រួលវគ្គបណ្តុះបណ្តាលស្តីពី សហគមន៍ដឹកនាំអនុវត្តអនាម័យ (CLTS) ដល់ជនបង្គោលអនាម័យឃុំ និងភូមិ ដែលរៀបចំដោយអង្គការជីវិតថ្លៃថ្នូ (LWD) នៅស្នាក់ការអង្គការជីវិតថ្លៃថ្នូរ (LWD) នៅភូមិបេង ឃុំចំបក់ ស្រុកភ្នំស្រួច។

- ថ្ងៃទី១៧-១៨ខែមីនា ឆ្នាំ២០២២ លោក រស់ សុផល បានចូលរួមសម្របសម្រួលវគ្គបណ្តុះបណ្តាលស្តីពី សហគមន៍ដឹកនាំ អនុវត្តន៍អនាម័យ (CLTS) ដល់ជនបង្គោលអនាម័យឃុំ និងជនបង្គោលអនាម័យភូមិ ដែលរៀបចំដោយអង្គការជីវិតថ្លៃថ្នូរ (LWD) នៅទីស្នាក់ការអង្គការ ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។
- ថ្ងៃទី៣០-៣១ខែមីនា ឆ្នាំ២០២២ លោក ឆែម សារិទ្ធ បានចូលរួមសម្របសម្រួលវគ្គបណ្តុះបណ្តាលស្តីពី កាតផ្សព្វផ្សាយអនាម័យសហគមន៍ (HP) ដល់ជនបង្គោលអនាម័យឃុំ និងជនបង្គោលអនាម័យភូមិ ដែលរៀបចំដោយអង្គការជីវិតថ្លៃថ្នូរ (LWD) នៅសាលប្រជុំសាលា ស្រុកឱរ៉ាល់ ខេត្ត កំពង់ ស្ពឺ ។

**៥.១៥. អង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍ (COCD)**

ថ្ងៃទី២៨-៣០ ខែធ្នូ ឆ្នាំ ២០២១ និងថ្ងៃទី ១១-១៣ ខែមករា ឆ្នាំ ២០២២ លោក រស់ សុផល និង លោក ឆែម សារិទ្ធ បានចូលរួមសម្របសម្រួលវគ្គបណ្តុះបណ្តាលស្តីពីការផ្លាស់ប្តូរឥរិយាបទក្នុងការអនុវត្ត អនាម័យរបស់សហគមន៍ (BCC) និងការថែទាំសុខភាពស្ត្រី (MHM) ដល់ជនបង្គោលអនាម័យឃុំ នៅស្រុកថ្ពង និងស្រុកឧដុង្គ ដែលរៀបចំដោយអង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍ (COCD)។

**៥.១៦. អង្គការវ៉ាត់ធើអេដ WaterAid**

ថ្ងៃទី១៧-១៨ ខែតុលា ឆ្នាំ២០២២ លោក ឆែម សារិទ្ធ អនុប្រធានការិ.ថែទាំសុខភាពជនបទ បានចូលរួមវេទិកាចែករំលែកចំណេះដឹង និងបទពិសោធន៍ ក្រោមប្រធានបទ អនាម័យក្នុងបរិស្ថានប្រឈម នៅសណ្ឋាគារកាំបូឌីយ៉ាណា។

## II. បញ្ហាប្រឈម

- ការប្រែប្រួលអាកាសធាតុ ធ្វើឲ្យប៉ះពាល់ដល់គម្រោងហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ
- កំណើនយានយន្ត ការដឹកលើសទម្ងន់កំណត់ និងបើកលើសល្បឿនកំណត់ធ្វើឲ្យផ្លូវជនបទធាប់ខូច និងមានគ្រោះថ្នាក់ចរាចរណ៍កើនឡើងញឹកញាប់
- ខ្វះការចូលរួមថែទាំផ្លូវជនបទ ពីថ្នាក់សហគមន៏ និងអ្នកប្រើប្រាស់ផ្លូវ
- ខ្វះគ្រួសក្រហមសម្រាប់សាងសង់ផ្លូវជនបទ
- ការយល់ដឹងពីអនាម័យ នៅតាមជនបទ នៅមានកម្រិត
- ការចូលរួមថែទាំអណ្តូងទឹក ស្រះទឹកពីសហគមន៏នៅមានកម្រិត
- ប្រជាពលរដ្ឋមានការយល់ដឹងតិចតួច ពីគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋជនបទ ធ្វើឲ្យខ្វះខាតកម្លាំងពលកម្ម នៅតំបន់ជនបទ
- ធនធានមនុស្ស សម្រាប់បម្រើការងារអភិវឌ្ឍនៅមានកម្រិត
- ថវិការដ្ឋដែលផ្តល់ជូននៅមានកម្រិត
- ការវិភាជន៍ថវិកា សម្រាប់ការងារហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដូចជាផ្លូវជនបទ អណ្តូង បង្គន់អនាម័យ ពុំទាន់សមស្របទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

## III. ទិសដៅការងារឆ្នាំ ២០២៣

### ៣.១. ការពង្រឹងស្ថាប័ន និងកសាងសមត្ថភាព

#### ៣.១.១. ការងាររដ្ឋបាល និងបុគ្គលិក

- ធ្វើរបាយការណ៍វឌ្ឍនភាពសម្រាប់ការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ តាមប្រព័ន្ធធនាគារ។
- ចុះលេខលិខិតចូល-ចេញ។
- ធ្វើឯកសារស្នើសុំដំឡើងថ្នាក់ និងឋានន្តរស័ក្តិជូនមន្ត្រីរាជការ នៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ។
- ធ្វើឯកសារស្នើសុំគ្រឿងឥស្សរិយយស និងមេដាយការងារជូនមន្ត្រីរាជការ នៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត។
- ធ្វើរបាយការណ៍ផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការស៊ីវិល នៃមន្ទីរ។
- ធ្វើការគ្រប់គ្រងបញ្ជីវត្តមានមន្ត្រីរាជការ របស់មន្ទីរ ។

**៣.១.២. ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងអប់រំផ្សព្វផ្សាយ ដល់មន្ត្រីរាជការ**

- បើកវគ្គផ្នែកកសិកម្ម ចិញ្ចឹមសត្វមាន់ចំនួន ០៥ វគ្គ
- បើកវគ្គផ្នែកកសិកម្ម ការដាំបន្លែចំនួន ០៥ វគ្គ
- បើកវគ្គផ្នែកកសិកម្ម ការចិញ្ចឹមត្រីចំនួន ០៣ វគ្គ
- បណ្តុះបណ្តាលជួសជុលអណ្តូងស្នប់។
- សហការជាមួយគម្រោង និងអង្គការដៃគូ។

**៣.១.៣. ការងារផែនការ-ស្ថិតិ**

- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ២០២៣។
- រៀបចំផែនការវិនិយោគ៣ឆ្នាំរំកិល ២០២៤-២០២៦ និងផែនការប្រចាំឆ្នាំ ២០២៤ របស់មន្ទីរជូនក្រសួង និងរដ្ឋបាលខេត្ត។

**៣.១.៤. ការងារគណនេយ្យ និងហិរញ្ញវត្ថុ**

- បន្តរៀបចំ ឯកសារប្រាក់បៀវត្សប្រចាំខែមករា ដល់ខែធ្នូ ឆ្នាំ ២០២៣។
- បន្តរៀបចំឯកសារ រដ្ឋទយ្យបុរេប្រទាន ចំនួន ៤ ជុំ។
- បន្តរៀបចំការងារកិច្ចលទ្ធកម្ម ចំនួន ០៧ គម្រោង ។
- បន្តរៀបចំឯកសារបញ្ជីសារពើភ័ណ្ឌឆ្នាំ ២០២៣។

**៣.២. ការងារអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍**

- ចុះធ្វើបច្ចុប្បន្នភាពទិន្នន័យផ្លូវជនបទចំនួន ៦៥ខ្សែ ប្រវែង ២១៥គ.ម និងស្រង់ខ្សែផ្លូវថ្មីចំនួន ១៧ខ្សែ ប្រវែង ៤៥គ,ម នៅទូទាំង៨ស្រុក ក្រុង។
- ចុះត្រួតពិនិត្យយានយន្តដឹកលើសទម្ងន់កម្រិតកំណត់លើខ្សែផ្លូវក្រាលកៅស៊ូ ៩៦លើក លើផ្លូវជនបទក្រាលកៅស៊ូ។

**៣.៣. ការងារកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ**

- ធ្វើបច្ចុប្បន្នភាពទិន្នន័យបង្គន់អនាម័យទូទាំងខេត្ត ប្រចាំខែ។
- បន្តចុះត្រួតពិនិត្យការអនុវត្តកម្មវិធី CLTS និងត្រួតពិនិត្យការការងារ នៅស្រុកឧដុង្គ ថ្ពង គងពិសី ឱរ៉ាល់ និងស្រុកសំរោងទង។

- បូកសរុបបញ្ជីឈ្មោះគ្រួសារក្រីក្រគ្មានលទ្ធភាពសាងសង់បង្គន់ប្រើប្រាស់ និងស្វែងរកដៃគូគាំទ្រ។
- ប្រជុំគណអភិបាលស្រុក និងក្រុមប្រឹក្សាស្រុក មេឃុំ ស្មៀន CWG ដើម្បីជំរុញផែនការ ODF ស្រុកមាន៖ ស្រុកឱរ៉ាល់ ឧដុង្គ និងស្រុកភ្នំស្រួច។
- សិក្សា និងប្រជុំផ្សព្វផ្សាយ ពីតម្លៃសាងសង់បង្គន់ តាមស្រុកគោលដៅ ទាំង៦ ។
- ប្រជុំតាមដាន ផែនការ ODF ស្រុកគោដៅប្រចាំខែ ត្រីមាស PWG និងPWG-S
- ប្រជុំតាមដានវឌ្ឍនភាពផែនការ ODF ឃុំ ។
- សាងសង់អណ្តូងស្នប់ចំនួន ២០ អណ្តូង( គម្រោង MRD/PDRD ២០២៣)។
- សហការជាមួយគម្រោង និងអង្គការដៃគូ ។

**៣ .៤.ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ**

- ចុះប្រមូលប្រាក់ និងផ្តល់ទុនឥណទានក្រុម នៅភូមិព្រៃមិច ១ ឃុំវាលពន់ ស្រុកថ្ពង។
- ធ្វើបច្ចុប្បន្នភាពជនជាតិដើមភាគតិចសួយ ចំនួន ០៥ ភូមិ ឃុំត្រពាំងជោរ ស្រុកឱរ៉ាល់។
- ប្រារព្ធពិធីទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោកខួបលើកទី ២៩ ឆ្នាំ ២០២៣ នៅឃុំត្រពាំងជោរ ស្រុកឱរ៉ាល់។
- ប្រជុំផ្សព្វផ្សាយគោលនយោបាយជាតិ ស្តីពី ការអភិវឌ្ឍជនជាតិដើមភាគតិចជាមួយសហគមន៍នៅឃុំត្រពាំងជោរ ស្រុកឱរ៉ាល់។

**៣.៥. គម្រោងកែលម្អផ្លូវជនបទជំហានទី៣ RRIP 3**

បន្តអនុវត្តគម្រោងកែលម្អផ្លូវជនបទជំហានទី៣RRIP-3ក្នុងការសាងសង់ផ្លូវក្រាលកៅស៊ូពីរជាន់ DBST ចំនួន ០៦ ខ្សែ ដែលមាន ប្រវែង ៨១.៩៩ គ.ម នៅស្រុកភ្នំស្រួច ឱរ៉ាល់ និងស្រុកសំរោងទង

**៣.៦. កិច្ចសហការជាមួយគម្រោងកម្មវិធីអភិវឌ្ឍន៍ផ្នែកសេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទជំហានទី៣ ក្រោមហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)**

- សាងសង់ប្រព័ន្ធចែកចាយទឹកសហគមន៍ខ្នាតតូចចំនួន០១កន្លែង សម្រាប់ប្រើប្រាស់ ៥ភូមិ ។
- សាងសង់អណ្តូងស្នប់ចំនួន ០៧ អណ្តូង។
- សាងសង់ពាងចំនួន ១ ១៧៥ ពាង។

**៣.៧. គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទទប់ទល់និងការបម្រែបម្រួលអាកាសធាតុ**

សាងសង់ផ្លូវក្រាលបេតុងចំនួន ៥ ខ្សែ ប្រវែង ២៣ គ.ម នៅស្រុកភ្នំស្រួច និងស្រុកសំរោងទង។

## សេចក្តីសន្និដ្ឋាន

លទ្ធផលដែលសម្រេចបាន ក្នុងរយៈពេលមួយឆ្នាំកន្លងទៅនេះ គឺពិតជាបានមកពីការខិតខំយកចិត្តទុកដាក់បំពេញភារកិច្ចប្រកបដោយភាពម្ចាស់ការ ទទួលខុសត្រូវខ្ពស់របស់មន្ត្រីរាជការ នៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ ជាពិសេសការដឹកនាំ របស់ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ និងនាយកដ្ឋានជំនាញ របស់ក្រសួង ដែលបានបង្កគ្រប់លក្ខណសម្បត្តិងាយស្រួល ទាំងស្មារតី សម្ភារៈ និងថវិកាជា

ប្រភពទុនដ៏សំខាន់អាចឲ្យមន្ទីរធ្វើការអនុវត្តនៅមូលដ្ឋានបានល្អប្រសើរតាមផែនការដែលបានគ្រោងទុក។

លទ្ធផលទាំងអស់ខាងលើនេះពិតជាពុំអាចខ្វះបាន ក្នុងការចូលរួមសហការពីស្ថាប័នពាក់ព័ន្ធ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋទូទាំងខេត្ត។ ការខិតខំយកចិត្តទុកដាក់បំពេញភារកិច្ចប្រកបដោយការអំណត់ព្យាយាមមុះមុតរបស់មន្ត្រីរាជការម្នាក់ៗ ដោយមានសាមគ្គីភាពរឹងមាំ និងក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ** ធ្វើឲ្យមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ ត្រូវបានការគាំទ្រ និងវាយតម្លៃខ្ពស់ពីអាជ្ញាធរខេត្ត ក្រុង-ស្រុក និងស្ថាប័នពាក់ព័ន្ធ។ លទ្ធផលទាំងអស់នេះពិតជាបានរួមចំណែក លើកកម្ពស់ជីវភាពរស់នៅ របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានឲ្យបានល្អប្រសើរជាងមុន និងបានចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ នៅតាមជនបទ ស្របតាមគោលដៅគោលនយោបាយជាយុទ្ធសាស្ត្ររបស់ក្រសួងអភិវឌ្ឍន៍ជនបទ ១០ ឆ្នាំ(២០២១-២០៣០) ធ្វើឲ្យប្រជាពលរដ្ឋនៅជនបទមានភាពស៊ីវិល័យ។